

# កម្មវិធីប្រមូលផល ដើមដៃ: ឥទ្ធិពលលើវិស័យ កសិកម្មកម្ពុជា


ហ៊ីង វុត្ថា និង នូ កែវសុទ្ធា



ភ្នំពេញ, ឧសភា ២០០៦



វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា



ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពី អុកស្វាមអាមេរិក

# កម្មវិធីប្រមូលផលដើមដៃ៖
# ឥទ្ធិពលលើវិស័យកសិកម្មកម្ពុជា

ហ៊ីង វុត្ថា និង នូ កែវសុធា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ, ខែឧសភា ឆ្នាំ២០០៦

របាយការណ៍នេះ បោះពុម្ពឡើងដោយមានជំនួយហិរញ្ញវត្ថុពី អង្គការអុកស្វាមអាមេរិក ។ អុកស្វាមអាមេរិក លើកកំពស់ឱ្យមានការវិភាគ និងចំណេះដឹងទូលំទូលាយជុំវិញបញ្ហានយោបាយ និងការអភិវឌ្ឍន៍សំខាន់ៗក្នុងតំបន់អាស៊ីបូព៌ា ។ ឯកសារនេះ គឺជាជំនួយដល់ការយល់ដឹងខាងលើ ។ ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ មិនមែនជាទស្សនៈរបស់ អុកស្វាមអាមេរិក ទេ ។

## បេសកកម្ម វិបសអ

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វិបសអ មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់អំពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។*

*វិបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

**© រក្សាសិទ្ធិឆ្នាំ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISBN-13: 978–99950–52-12-6**

**កម្មវិធីប្រមូលផលដើមដៃ: ឥទ្ធិពលលើវិស័យកសិកម្មកម្ពុជា ~ *របាយការណ៍ពិសេសលេខ ៤***

ខែឧសភា ឆ្នាំ២០០៦

*ហ៊ីង វុត្ថា និង នូ កែវសុទ្ធា*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ហើយក៏មិនមែនជារបស់ អុកស្វាមអាមេរិកដែរ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)

ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤

**អ៊ីមែល:** cdri@camnet.com.kh **website:** http://www.cdri.org.kh

កែសម្រួល និងរចនាដោយ: អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ

បកប្រែដោយ: ហ៊ីង វុត្ថា

បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន

# មាតិកា


សេចក្តីសង្ខេប ........ ១

បញ្ជីអក្សរកាត់ ........ ៣

សេចក្តីថ្លែងអំណរគុណ ........ ៥

**ជំពូកទី ១. សេចក្តីផ្តើម ........ ៧**

១.១ ប្រវត្តិនៃការសិក្សា ........ ៧

១.២ គោលបំណងនៃការស្រាវជ្រាវ ........ ៩

១.៣ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៩

១.៤ រចនាសម្ព័ន្ធ ........ ១០

**ជំពូកទី ២. តំបន់ពាណិជ្ជកម្មអាស៊ាន-ចិនៈ សនិទានភាព អត្ថប្រយោជន៍សេដ្ឋកិច្ច និងលក្ខណៈពិសេស ........ ១១**

២.១. សនិទានភាពនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ........ ១១

២.២. ផលចំណេញ និងបញ្ហាប្រឈមខាងសេដ្ឋកិច្ចនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ........ ១២

២.៣ លក្ខណៈពិសេសរបស់កិច្ចព្រមព្រៀងក្របខ័ណ្ឌ ........ ១៣

**ជំពូកទី ៣. ផលប៉ះពាល់សក្តានុពលនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ........ ១៩**

៣.១. ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និង ចិន ........ ១៩

៣.២. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនៈ ឱកាសនិងបញ្ហាប្រឈមសំរាប់កម្ពុជា ........ ២២

៣.៣. ឥទ្ធិពលជាសក្តានុពលនៃកម្មវិធីប្រមូលផលដើមដៃលើវិស័យកសិកម្មកម្ពុជា ........ ២៤

៣.៤. ផលប៉ះពាល់លើភាពក្រីក្រ ........ ២៥

**ជំពូកទី ៤. កិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជា ........ ២៧**

៤.១. ថ្នាក់សាកលលោក ........ ២៧

៤.២. ថ្នាក់តំបន់ ........ ២៨

៤.៣ សរុបសេចក្តី ........ ៣០

**ជំពូកទី ៥ ឧបសគ្គ និងដំណោះស្រាយ ........ ៣១**

៥.១. បញ្ហាទូទៅក្នុងវិស័យកសិកម្ម និងអាជីវកម្ម ........ ៣១

៥.២. អនុសាសន៍ចំពោះគោលនយោបាយ ........ ៣៣

**ជំពូកទី ៦ សេចក្តីសន្និដ្ឋាន............................................................................................................ ៣៧**

ឯកសារយោង............................................................................................................................ ៣៩
ឧបសម្ព័ន្ធ.................................................................................................................................. ៤១
ឧបសម្ព័ន្ធស្ថិតិ.............................................................................................................................៤៤
បញ្ជីឯកសារពិភាក្សារបស់ វិបសអ ........................................................................................... ៤៧

# សេចក្តីសង្ខេប


ការសិក្សានេះពិនិត្យមើលលើការវិវត្តន៏ លក្ខណៈពិសេស និងផលប៉ះពាល់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន លើសេដ្ឋកិច្ចតំបន់ ។ ការសិក្សានេះផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើផលចំណេញសេដ្ឋកិច្ចនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនចំពោះប្រទេសកម្ពុជា ឥទ្ធិពលនៃកម្មវិធីប្រមូលផលដើមដៃ (EHP) លើវិស័យកសិកម្ម និងគោលនយោបាយឆ្លើយតប ដើម្បីកម្ពុជាអាចទាញប្រយោជន៏បានច្រើនបំផុត ពីកម្មវិធីប្រមូលផលដើមដៃនេះ ។ ការវិភាគផ្អែកជាសំខាន់លើការពិគ្រោះយោបល់ស៊ីជំរៅជាមួយអ្នកជាប់ពាក់ព័ន្ធសំខាន់ៗ និងផ្អែកលើការវិភាគទិន្នន័យនៃរចនាសម្ព័ន្ធពាណិជ្ជកម្មកម្ពុជា និងចិន ដោយយោងលើគំរូពាណិជ្ជកម្មរវាងចិន ហើយនិង ថៃនិងវៀតណាម ។

ការសិក្សានេះបានរកឃើញថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ផ្តល់សារៈប្រយោជន៏ និងផលចំណេញសេដ្ឋកិច្ចដល់ប្រទេសសមាជិកទាំងអស់ តាមរយៈការបង្កើនសកម្មភាពពាណិជ្ជកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច វិនិយោគ និងការពង្រឹងកិច្ចសហប្រតិបត្តិការ ។ ការលុបបំបាត់របាំងពាណិជ្ជកម្មរវាងអាស៊ាន-ចិន អាចកាត់បន្ថយថ្លៃដើម បង្កើនសកម្មភាពពាណិជ្ជកម្មអន្តរតំបន់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និងកែលំអលទ្ធភាពវិនិយោគនៅក្នុងតំបន់ ។ សំរាប់ប្រទេសកម្ពុជា កម្មវិធីប្រមូលផលដើមដៃ ដែលមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ក្នុងគោលបំណងបង្កើនល្បឿនសេរីភាវូបនីយកម្មពាណិជ្ជកម្មលើផលិតផលកសិកម្ម អាចនឹងផ្តល់ឪកាសដើម្បីអភិវឌ្ឍវិស័យកសិកម្ម ដែលជាប្រភពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ការអភិវឌ្ឍន៏វិស័យកសិកម្មតាមកម្មវិធីនេះ អាចធ្វើទៅបានតាមរយៈការនាំចេញទៅទីផ្សារប្រទេសចិននូវផលិតផលមួយចំនួនដូចជា ផ្លែឈើស្រស់ សត្វចិញ្ចឹម ត្រី និងបង្គា ។ ប៉ុន្តែផលចំណេញទាំងនេះពុំទាន់សំរេចបាននៅឡើយទេ ពីព្រោះប្រទេសកម្ពុជាពុំទាន់បំពេញបានគ្រប់គ្រាន់នូវលក្ខខណ្ឌដំបូងនៃបរិយាកាសជំនួញ ក្របខ័ណ្ឌច្បាប់ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងស្ថាប័នសាធារណៈដ៏មានប្រសិទ្ធភាព ។ ជាលទ្ធផល សមត្ថភាពប្រកួតប្រជែងនៃវិស័យកសិកម្ម និងសហគ្រាសនៅប្រទេសកម្ពុជា បន្តមានកំរិតទាប ។

ប្រទេសកម្ពុជាគួរតែដោះស្រាយឧបសគ្គចំបងៗចំពោះការអភិវឌ្ឍន៏កសិកម្ម និងឧបសគ្គចំពោះសមត្ថភាពផ្គត់ផ្គង់ ទើបអាចទាញផលចំណេញបានច្រើនពីកម្មវិធីប្រមូលផលដើមដៃ ។ កំណែទំរង់រដ្ឋបាល ច្បាប់ និងប្រព័ន្ធយុត្តិធមិ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានគ្រប់គ្រាន់ ហើយនិងក្របខ័ណ្ឌច្បាប់និងគោលនយោបាយអំណោយផលល្អ គឺជាបញ្ហាអាទិភាពដែលរដ្ឋាភិបាលគួរតែដោះស្រាយ ។ លើសពីនេះទៀត ការកែលំអផលិតភាពកសិកម្ម ការបង្កើនសមត្ថភាពផលិតកម្មរបស់សហគ្រាស ការកាត់បន្ថយចំណាយលើពាណិជ្ជកម្ម និងការពង្រឹងកិច្ច សហប្រតិបត្តិការរវាងសមាគមអ្នកជំនួញនៃកម្ពុជា និង ចិន ក៏មានសារៈសំខាន់ណាស់ដែរដល់ការបង្កើនសកម្មភាព ពាណិជ្ជកម្មកសិកម្មរបស់កម្ពុជា ។

ដើម្បីអោយកម្មវិធីប្រមូលផលដើមដៃ មានឥទ្ធិពលខ្លាំងក្លាលើការកាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលគួរតែមានការគាំទ្រនិងគោលនយោបាយដើម្បីជំរុញអោយអ្នកក្រីក្រចូលរួមអោយបានច្រើន ក្នុងសេរីភាវូបនីយកម្ម និងកំណើនពាណិជ្ជកម្ម ។ រដ្ឋាភិបាលគួរតែរៀបចំវិធានការកែសំរួលដ៏សមរម្យ ដើម្បីកាត់បន្ថយឥទ្ធិពល អវិជ្ជមានដែលអាចកើតមានលើអ្នកក្រីក្រ ។ អនាគតនៃវិស័យកសិកម្ម និងការរួមចំណែកនៃកម្មវិធីប្រមូលផលដើមដៃ ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺផ្អែកលើជោគជ័យនៃគោលនយោបាយ និងកម្មវិធីកំណែទំរង់របស់រដ្ឋាភិបាល ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងរបស់វិស័យកសិកម្ម និងសហគ្រាស ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| CEPT | គំរោងអនុគ្រោះពន្ធគយរួម |
| EHP | កម្មវិធីប្រមូលផលដើមដៃ |
| FDI | វិនិយោគផ្ទាល់ពីបរទេស |
| FTA | តំបន់ពាណិជ្ជកម្មសេរី |
| GATT | កិច្ចព្រមព្រៀងទូទៅស្ដីពីតារាងពន្ធគយ និងពាណិជ្ជកម្ម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GEL | បញ្ជីទំនិញលើកលែងទូទៅ |
| GMS | មហាអនុតំបន់ទន្លេមេគង្គ |
| HS | ប្រព័ន្ធសំរបសំរួល |
| IL | បញ្ជីទំនិញរាប់បញ្ចូល |
| MFN | ប្រជាជាតិទទួលការអនុគ្រោះបំផុត |
| SADZ | តំបន់អភិវឌ្ឍន៍កសិកម្មពិសេស |
| SL | បញ្ជីទំនិញរសើប |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| TEL | បញ្ជីទំនិញលើកលែងបណ្ដោះអាសន្ន |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅដល់លោក Matthew Coghlan មន្ត្រីគោលនយោបាយពាណិជ្ជកម្មតំបន់នៃអង្គការ អុកស្វាមអាមេរិក និង Dr. Brett M. Ballard នាយកស្រាវជ្រាវស្តីទីនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលបានផ្តល់ការគាំទ្រ និងការពិគ្រោះយោបល់ខាងបច្ចេកទេស ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ Dr. K.A.S. Murshid, Dr. Brett M. Ballard, Matthew Coghlan និង Raquel Gomes ដែលបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ព្រាង ។

ក្រុមអ្នកនិពន្ធសូមសំដែងអំណរគុណដល់លោក ណុប សោភ័ណ្ឌតារា អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម ដែលបានផ្តល់គំនិតដ៏មានតំលៃលើបញ្ហាផ្សេងៗក្នុងអំឡុងពេលជំនួបពិគ្រោះយោបល់ស៊ីជំរៅ ។ យើងខ្ញុំក៏សូមអរគុណដល់តំណាងក្រុមហ៊ុននាំចេញនាំចូល ដែលបានចំណាយពេលវេលា ចែករំលែកបទពិសោធន៍ជាក់ស្តែង និងការយល់ដឹងជាមួយយើងខ្ញុំ ។

ជាទីបញ្ចប់ អ្នកនិពន្ធ និង CDRI សូមសំដែងសេចក្តីដឹងគុណដ៏ស្មោះស្ម័គ្រដល់អង្គការ អុកស្វាមអាមេរិក ដែលបានផ្តល់ជំនួយគាំទ្រដ៏សប្បុរសដល់គំរោងស្រាវជ្រាវនេះ ។

# ជំពូកទី ១. សេចក្តីផ្តើម

## ១.១. ប្រវត្តិនៃការសិក្សា

ទំនាក់ទំនងរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន ចាប់ផ្តើមជាផ្លូវការតាំងពីឆ្នាំ ១៩៩៤ នៅពេលដែលចិនបានចូលរួមក្នុងវេទិការតំបន់អាស៊ាន និងបន្ទាប់មកបានក្លាយជាដៃគូអាស៊ានក្នុងឆ្នាំ១៩៩៦ ។ ទំនាក់ទំនងអាស៊ាន-ចិនចាប់ផ្តើមរីកចំរើនខ្លាំង នៅពេលមានការបង្កើតគណៈកម្មការសហប្រតិបត្តិការរួមអាស៊ាន-ចិន មូលនិធិសហប្រតិបត្តិការអាស៊ាន-ចិន និងកិច្ចប្រជុំកំពូលអាស៊ាន-ចិនជាបន្តបន្ទាប់ ។ សហប្រតិបត្តិការរវាងអាស៊ាន-ចិនក្នុងវិស័យពាណិជ្ជកម្ម វិនិយោគទុន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សន្តិសុខ កសិកម្ម និងការអភិវឌ្ឍន៍ធនធានមនុស្ស ក៏ត្រូវបានពង្រឹងយ៉ាងឆាប់រហ័សផងដែរ ។ ឧទាហរណ៍ ពាណិជ្ជកម្មក្រៅប្រទេស រវាងប្រទេសទាំងពីរបានកើនឡើងពី ១១,០៦ពាន់លានដុល្លារក្នុងឆ្នាំ ១៩៩៤ ដល់ ៣៩,៥ពាន់លានដុល្លារក្នុងឆ្នាំ២០០០ ។ ក្នុងឆ្នាំ១៩៩១ វិនិយោគទុនរបស់អាស៊ានក្នុងប្រទេសចិនមានចំនួនតែ ៩០លានដុល្លារប៉ុណ្ណោះ ប៉ុន្តែចំនួននេះបានកើនឡើងដល់ ៤,៨ពាន់លានដុល្លារ ក្នុងឆ្នាំ១៩៩៨ និង ២៦,២ពាន់លានដុល្លារ ក្នុងឆ្នាំ២០០១ ។រីឯវិនិយោគទុនរបស់ចិនក្នុងតំបន់អាស៊ានមានចំនួន ១,១ពាន់លានដុល្លារ ក្នុងឆ្នាំ២០០១ ។

ដោយសារការវិវត្តន៍ដ៏លឿនបែបនេះ ព្រមទាំងកំនើននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មក៏រិតតំបន់នៅជុំវិញពិភពលោក តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ត្រូវបានគេស្នើឡើងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន + ៣ ក្នុងខែវិច្ឆិកា ឆ្នាំ២០០០ ។ កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងចិន (កិច្ចព្រមព្រៀងក្របខ័ណ្ឌ) ត្រូវបានចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី ៨ នៅភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ក្នុងគោលបំណងពង្រឹងបន្ថែមលើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគទុន និងដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរី ក្នុងរយៈពេល ១០ឆ្នាំ ។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងបង្កើតទីផ្សារតំបន់មួយ ដែលមានអតិថិជនរហូតដល់ ១,៧ពាន់លាននាក់ និងផលិតផលក្នុងស្រុកសរុបក្នុងតំបន់មានតំលៃប្រហែល ២.០០០ពាន់លានដុល្លារ រីឯពាណិជ្ជកម្មក្រៅប្រទេសសរុបតាមការប៉ាន់ស្មានមានចំនួន ១.២៣០ពាន់លានដុល្លារ (ASEAN-China Expert Group, 2001) ។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងក្លាយទៅជាតំបន់ពាណិជ្ជកម្មសេរីដ៏ធំជាងគេបង្អស់ក្នុងពិភពលោក បើគិតតាមចំនួនប្រជាជន និងជាតំបន់ធំជាងគេបង្អស់ដែលមានប្រទេសកំពុងអភិវឌ្ឍន៍ចូលរួម បើគិតតាមទំហំ ផសស និងសកម្មភាពពាណិជ្ជកម្ម ។

យោងតាមទ្រឹស្តីសេដ្ឋកិច្ច តំបន់ពាណិជ្ជកម្មសេរី ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់គ្រប់ប្រទេសសមាជិក ចាប់ពីប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ រហូតដល់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងភាពជាដៃគូយ៉ាងជិតស្និទ្ធ ក្នុងវិស័យមិនមែនសេដ្ឋកិច្ចដូចជា សន្តិភាព និងស្ថិរភាព ។ ការលុបបំបាត់របាំងពាណិជ្ជកម្ម អាចកាត់បន្ថយចំណាយថ្លៃដើម បង្កើនសកម្មភាពពាណិជ្ជកម្មអន្តរតំបន់ និងប្រសិទ្ធភាពសេដ្ឋកិច្ច ។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងបង្កើនការនាំចេញរបស់អាស៊ានទៅកាន់ប្រទេសចិនដល់ចំនួន ១៣ពាន់លានដុល្លារ ឬ កើនឡើង ៤៨% និងបង្កើនការនាំចេញរបស់ចិន ទៅកាន់តំបន់អាស៊ានដល់ចំនួន ១០,៦ពាន់លានដុល្លារ រឺកើនឡើង ៥៥,១% (ASEAN-China Expert Group, 2001) ។ ក្រៅពីនេះ តំបន់ពាណិជ្ជកម្មសេរី នឹងទាក់ទាញវិនិយោគទុនកាន់តែច្រើនចូលក្នុងតំបន់ ។ មិនត្រឹមតែក្រុមហ៊ុននៅក្នុងតំបន់អាស៊ាន និងចិនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង

មានក្រុមហ៊ុនមកពីប្រទេសផ្សេងទៀតក្នុងពិភពលោក ជាពិសេសអាមេរិក សហគមន៍អឺរ៉ុប និងជប៉ុន ដែលមានបំណងវិនិយោគទុនក្នុងទីផ្សារសមាហរណកម្មនេះ ។ ក្នុងរយៈពេលវែង នៅពេលទីផ្សាររីកកាន់តែធំជាងមុន មានការប្រកួតប្រជែងកាន់តែខ្លាំង ហើយវិនិយោគ និងមាត្រដ្ឋានសេដ្ឋកិច្ចមានការកើនឡើង ពេលនោះអ្នកវិនិយោគអាចមាននិន្នាការកាន់តែខ្លាំងក្នុងការមកវិនិយោគទុននៅក្នុងតំបន់នេះ ។

ក្នុងនាមជាប្រទេសមួយសំរេចបានសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក តាមរយៈសមាជិកភាពក្នុងអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ (GMS) និងអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាបានចាត់ទុកកិច្ចព្រមព្រៀងក្របខ័ណ្ឌជាយន្តការសំខាន់មួយ ដើម្បីពង្រឹងសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ និងដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ។ កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ទំនងជាបង្កើតអោយមានទាំងឱកាសសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចដល់កម្ពុជា ។ ផលចំណេញសេដ្ឋកិច្ចរួមមាន ការជំរុញសកម្មភាពពាណិជ្ជកម្ម វិនិយោគ ប្រសិទ្ធភាពសេដ្ឋកិច្ច និងសុខមាលភាព រីឯឱកាសមិនមែនសេដ្ឋកិច្ច អាចជាការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើន ដូចជា ទេសចរណ៍ ការអភិវឌ្ឍន៍ធនធានមនុស្សនិងសន្តិសុខ ព្រមទាំងកិច្ចសហប្រតិបត្តិការប្រសើរជាមុនរវាងចិន និងកម្ពុជា ក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

កម្មវិធីប្រមូលផលដើមដៃ គឺជាបញ្ញត្តិមួយដែលចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដើម្បីបង្កើនល្បឿននៃការអនុវត្តន៍សេរីភាវូបនីយកម្មកសិកម្ម ។ កម្មវិធីនេះ រាប់បញ្ចូលក្រុមផលិតផលកសិកម្មចំនួន ៨ក្រុមដូចជា សត្វរស់ សាច់និងគ្រឿងក្នុងអាចបរិភោគបាន ត្រី ផលិតផលពីទឹកដោះ ផលិតផលធ្វើពីសត្វផ្សេងទៀត ដើមរុក្ខជាតិរស់ បន្លែនិងផ្លែឈើ និងគ្រាប់ផ្លែឈើ ។ កិច្ចព្រមព្រៀងក៏បានកំណត់រយៈពេល ៣ឆ្នាំ គិតចាប់តាំងពីខែមករា ឆ្នាំ២០០៤ ដើម្បីអនុវត្តកម្មវិធីនេះ ហើយវាបានផ្តល់ប្រព្រឹត្តិកម្ម និងការអនុគ្រោះពិសេស និងភាពបត់បែនច្រើនដល់ប្រទេសសមាជិកអាស៊ានថ្មី (កម្ពុជា ឡាវ ភូមា និងវៀតណាម) រហូតដល់ឆ្នាំ២០១០ សំរាប់ការកាត់បន្ថយ និងលុបបំបាត់ចោលតារាងពន្ធគយ ។

កម្មវិធីប្រមូលផលដើមដៃ គឺជាឱកាសសំរាប់ឱ្យកម្ពុជាអភិវឌ្ឍវិស័យកសិកម្ម ដើម្បីជាប្រភពថ្មីមួយទៀតនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើនការនាំចេញផលិតផលកសិកម្ម ។ ទោះបីជា ពាណិជ្ជកម្មកម្ពុជា-ចិន ក្នុងមុខផលិតផលនៃកម្មវិធីនេះ មិនសូវសំខាន់ក្តី (មានតែ ០,៣៣% នៃពាណិជ្ជកម្មសរុបនៅឆ្នាំ២០០០-០៥) ក៏ច្រកចូលទីផ្សារដ៏ធំមានថាមពលខ្លាំងរបស់ប្រទេសចិន នឹងផ្តល់សក្តានុពលយ៉ាងខ្លាំងសំរាប់ការនាំចេញផលិតផលកសិកម្មរបស់ប្រទេសកម្ពុជា ។ ត្រីរស់ គឺជាផលិតផលនាំចេញធំបំផុតរបស់កម្ពុជាកំឡុងឆ្នាំ២០០០-២០០៥ ដែលមានតំលៃ ៣,៩៩លានដុល្លារ បន្ទាប់មកមានបង្គារ សត្វរស់ និងផ្សិត ។ ក្នុងកំឡុងពេលដូចគ្នានេះដែរ ខ្ទឹមស គឺជាផលិតផលនាំចូលដល់ធំជាងគេពីប្រទេសចិន បន្ទាប់មកមានផ្លែប៉ោម ផ្សិត ផ្លែព័រនិងផ្លែក្រូចឃ្វិចស៊ី សំណែកក្របាម ទឹកឃ្មុំ និងត្រី ។ រចនាសម្ព័ន្ធពាណិជ្ជកម្មកម្ពុជា-ចិន និងបទពិសោធន៍នៃប្រទេសផ្សេងទៀតបញ្ជាក់ថា កម្មវិធីប្រមូលផលដើមដៃ នឹងផ្តល់ឱកាសដ៏ប្រពៃដល់កម្ពុជា ដើម្បីនាំចេញផលិតផលកសិកម្មទៅប្រទេសចិន ដោយមានទាំងផលិតផលនាំចេញពេលបច្ចុប្បន្នដូចជា ត្រី បង្គារ និងផលិតផលនាំចេញសក្តានុពលជាច្រើនទៀតដូចជា ជំឡូងឈើ គ្រាប់ស្វាយចាន់ទី ហើយនិងផ្លែឈើស្រស់ ដូចជា ធូរេន ម្នាស់ មៀន និងចេក ។ ដោយសារសមត្ថភាពប្រកួតប្រជែងលើផលិតផលទាំងនេះរបស់កម្ពុជានៅទាបជាងវៀតណាម និងថៃ កម្ពុជាគួរតែតំរង់រកប្រភេទទីផ្សារជាក់លាក់ណាមួយសំរាប់ផលិតផលកសិកម្មរបស់ខ្លួនដោយផ្អែកលើរសជាតិប្លែកពីគេ ។

ម្យ៉ាងទៀត កម្មវិធីប្រមូលដើមដៃ ក៏អាចបង្កបញ្ហាមួយចំនួនដល់ប្រទេសកម្ពុជា ជាពិសេសផលិតផលនាំចូលពីចិន អាចរុញផលិតករក្នុងស្រុកចេញពីទីផ្សារ ។ ប៉ុន្តែដោយសាររចនាសម្ព័ន្ធពាណិជ្ជកម្មកម្ពុជា-ចិន មានលក្ខណៈបំពេញអោយគ្នាទៅវិញទៅមក ឥទ្ធិពលអវិជ្ជមានរបស់កម្មវិធីនេះចំពោះកម្ពុជា ពុំមានទ្រង់ទ្រាយធំណាស់ណាទេ ។ ដូច្នេះវិស័យកសិកម្មកម្ពុជា នឹងពុំទទួលរងការប៉ះពាល់ជាអវិជ្ជមានខ្លាំងក្លាដោយសារកម្មវិធីនេះទេ យ៉ាងហោចណាស់ក្នុងរយៈពេលខ្លី និងមធ្យម ។

រហូតមកដល់បច្ចុប្បន្ន មានការសិក្សាតិចតួចណាស់ស្តីពីផលចំណេញ និងការខាតបង់ខាងសេដ្ឋកិច្ចនៃកម្មវិធីប្រមូលផលដើមដៃនេះ មកលើវិស័យកសិកម្មកម្ពុជា ព្រមទាំងគោលនយោបាយឆ្លើយតបផ្សេងៗ ។ ការសិក្សានេះ ព្យាយាមបំពេញចំណុចចន្លោះប្រហោងដោយឆ្លើយនឹងសំនួរសំខាន់ៗដូចខាងក្រោមៈ តើកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកម្មវិធីប្រមូលផលដើមដៃមានឥទ្ធិពលអ្វីខ្លះលើកម្ពុជា និងវិស័យកសិកម្មរបស់កម្ពុជា? តើអ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយរបស់រដ្ឋាភិបាល គួរធ្វើអ្វីខ្លះនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ដើម្បីអោយប្រទេសកម្ពុជា ទាញផលចំណេញបានច្រើនបំផុតពីកម្មវិធីប្រមូលផលដើមដៃ និងដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានរបស់វា?

## ១.២. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងរួមពីរគឺ (១) បង្ហាញពីអត្តសញ្ញាណ ចំណេះដឹង និងការយល់ដឹងអំពី កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងបែបតំបន់ដែលរាប់ទាំងកម្មវិធីប្រមូលផលដើមដៃ និង (២) ស្វែងយល់អំពីឥទ្ធិពលដែលអាចមានពីកម្មវិធីប្រមូលផលដើមដៃមកលើកម្ពុជាជាទូទៅ និងចំពោះវិស័យកសិកម្មរបស់កម្ពុជា ។

ការសិក្សានេះមានគោលបំណងសំខាន់ជាក់លាក់បួនគឺ (១) វិភាគលើលក្ខណៈពិសេសសំខាន់ៗរបស់កម្មវិធីប្រមូលផលដើមដៃ និងរិះរកឱកាស និងបញ្ហាប្រឈមរបស់កម្មវិធីនេះដល់តំបន់ទាំងមូល និងកម្ពុជា (២) វាយតំលៃពីឥទ្ធិពលសក្តានុពលរបស់កម្មវិធីប្រមូលផលដើមដៃ លើការនាំចេញនិងនាំចូលផលិតផលកសិកម្ម និងលើផលិតករក្នុងស្រុក (៣) រិះរកគោលនយោបាយឆ្លើយតប ដើម្បីជំរុញការនាំចេញផលិតផលកសិកម្ម បង្កើនសមត្ថភាពផ្គត់ផ្គង់ និងដើម្បីធ្វើអោយកម្មវិធីប្រមូលផលដើមដៃនេះចូលរួមកាត់បន្ថយភាពក្រីក្រ និង (៤) រិះរកប្រធានបទសំរាប់ការស្រាវជ្រាវបន្ថែម ។

## ១.៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពីរបែប គឺការស្រាវជ្រាវលើឯកសារមានស្រាប់ (Desk research) និងការសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (Key informant interview ) ។

__ការស្រាវជ្រាវលើឯកសារមានស្រាប់:__ ការសិក្សាសំខាន់ៗលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកម្មវិធីប្រមូលផលដើមដៃត្រូវបានរំលឹកឡើងវិញ ។ ទិន្នន័យពីរចនាសម្ព័ន្ធពាណិជ្ជកម្មកម្ពុជា-ចិន និងរចនាសម្ព័ន្ធពាណិជ្ជកម្មរវាង ថៃ វៀតណាម និងចិន ត្រូវបានពិនិត្យយ៉ាងម៉ត់ចត់ ដើម្បីធ្វើការវាយតំលៃពីផលប៉ះពាល់លើពាណិជ្ជកម្ម ផលិតផលកសិកម្ម និងវិស័យកសិកម្ម ។ នៅមានការពិនិត្យឡើងវិញលើឯកសារគោលនយោបាយ ជាពិសេសឯកសារទាក់ទងនឹងពាណិជ្ជកម្ម បរិយាកាសវិនិយោគ និងឧបសគ្គនានាលើការអភិវឌ្ឍន៍កសិកម្ម និងពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ។ បន្ទាប់ពីការសិក្សាឡើងវិញនេះ មានការបង្កើតជាអនុសាសន៍គោលនយោបាយដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងរបស់វិស័យកសិកម្ម និងសហគ្រាសនៅកម្ពុជា ។

__ការសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ:__ ការសំភាសន៍ និងពិភាក្សាជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗជាច្រើននាក់មកពីក្រុមហ៊ុននាំចេញ-នាំចូល ដើម្បីស្វែងយល់ពីគំនិត និងការយល់ដឹងរបស់ពួកគេ ចំពោះកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។ បទសំភាសន៍បានរកឃើញចម្លើយតបចំពោះការផ្សព្វផ្សាយគោលនយោបាយ សេវាគាំពារអាជីវកម្ម និងការ អនុវត្តន៍របស់រដ្ឋាភិបាល ។ លើសពីនេះ ក៏មានការសំភាសន៍ពិគ្រោះយោបល់ស៊ីជំរៅជាមួយមន្ត្រីជាន់ខ្ពស់មកពីក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្វែងយល់ពីធាតុពិតនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកម្មវិធីប្រមូលផលដើមដៃ តាមទស្សនៈរបស់អ្នកកសាងគោលនយោបាយ និងពិនិត្យមើលពីវិធីអនុវត្តន៍តារាងពេលវេលាធ្វើ សេរីភាវូបណីយកម្ម ។

## ១.៤. រចនាសម្ព័ន្ធ

ឯកសារសិក្សានេះត្រូវបានរៀបចំដូចខាងក្រោម ។ ជំពូកទី ២ អធិប្បាយអំពីលក្ខណៈពិសេសសំខាន់ៗរបស់កិច្ចព្រមព្រៀងក្របខ័ណ្ឌដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកម្មវិធីប្រមូលផលដើមដៃ ។ ក្នុងនេះ មានការអធិប្បាយពីសនិទានភាព (មូលហេតុ) ឱកាស និងបញ្ហាប្រឈមនៃតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន ។ ជំពូកទី ៣ ពិភាក្សាអំពីផលប៉ះពាល់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនមកលើកម្ពុជា ជាពិសេសអំពីផលប៉ះពាល់សក្តានុពលរបស់កម្មវិធីប្រមូលផលដើមដៃលើវិស័យកសិកម្មកម្ពុជា ។ នៅមានការរៀបរាប់ត្រួសៗ ពីទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងចិន ព្រមទាំងការសិក្សាឡើងវិញពីឱកាស និងបញ្ហាប្រឈមនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនលើប្រទេសកម្ពុជា និងមានការវាយតំលៃពីផលប៉ះពាល់ជាសក្តានុពលនៃកម្មវិធីប្រមូលផលដើមដៃលើវិស័យកសិកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើឱកាសនាំចេញ បញ្ហាប្រឈម និងផលប៉ះពាល់នៃភាពក្រីក្រ ។ ជំពូកទី ៤ ពិនិត្យពីកិច្ចព្រមព្រៀងពាណិជ្ជកម្មក៏រិតពិភពលោក តំបន់ និងទ្វេភាគី ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា ។ ជំពូកទី ៥ ពិភាក្សាពីកំហិតនានាចំពោះវិស័យកសិកម្ម និងឧបសគ្គចំបងៗ ដល់ដំណើរការ និងកំណើនអាជីវកម្មដែលរារាំងកម្ពុជា ជាពិសេសវិស័យកសិកម្ម មិនអោយទទួលបានផលចំណេញពេញលេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងៗ ព្រមទាំងមានការស្នើជាអនុសាសន៍ និងគោលនយោបាយឆ្លើយតបជាច្រើន ដើម្បីដោះស្រាយឧបសគ្គទាំងនេះ និងដើម្បីបង្កើនសមត្ថភាពសហគ្រាសកម្ពុជា ។ ជំពូកទី ៦ ផ្តល់សេចក្តីសន្និដ្ឋាន ។

# ជំពូកទី ២. តំបន់ពាណិជ្ជកម្មអាស៊ាន-ចិនៈ សនិទានភាព អត្ថប្រយោជន៍សេដ្ឋកិច្ច និងលក្ខណៈពិសេស

ជំពូកនេះពិនិត្យលើតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ក្នុងបរិបទនៃមូលហេតុ អត្ថប្រយោជន៍សេដ្ឋកិច្ចជាសក្តានុពល និងលក្ខណៈពិសេសៗ ។ វាចាប់ផ្តើមដោយពិភាក្សាលើមូលហេតុនៃការបង្កើតតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន និងអត្ថប្រយោជន៍សេដ្ឋកិច្ច ពីទស្សនៈភាគីទាំងពីរអាស៊ាន និងចិន ។ បន្ទាប់មកមានការពិភាក្សាទៅលើលក្ខណៈពិសេសសំខាន់ៗរបស់កិច្ចព្រមព្រៀងក្របខ័ណ្ឌ ដោយផ្តោតលើកម្មវិធីប្រមូលផលដើមដៃ ពាក់ព័ន្ធនឹងការរាយមុខផលិតផល ទំរង់បែបផែនសំរាប់ការកាត់បន្ថយនិងលុបបំបាត់តារាងពន្ធគយ និងពេលវេលាអនុវត្តន៍ ។

## ២.១. សនិទានភាពនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន

មូលហេតុនៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន មានទាំងលក្ខណៈសេដ្ឋកិច្ច និងនយោបាយ ។ បណ្តាប្រទេសអាស៊ានបានស្វាគមន៍គំនិតអោយមានតំបន់ពាណិជ្ជកម្មសេរីជាមួយចិន មានហេតុផលជាច្រើន ។ ទី១ ចិនជាប្រទេសមានសេដ្ឋកិច្ចធំ និងខ្លាំង ហើយកំណើនតំរូវការនៃទំនិញ និងសេវាកម្មរបស់ចិនពីអាស៊ាន អាចជាម៉ាស៊ីនថ្មីមួយនៃកំណើនសេដ្ឋកិច្ច (China, 2004) ។ អាស៊ានចាត់ទុកចិន ថាជាទីផ្សារនាំចេញចំបងទៅអនាគតសំរាប់ទំនិញវត្ថុធាតុដើមថាមពល និងគ្រឿងបន្លាស់ម៉ាស៊ីន និងឧបករណ៍អេឡិចត្រូនិក ។ ទំនាក់ទំនងសេដ្ឋកិច្ចកាន់តែប្រសើររវាងអាស៊ាន-ចិន ក៏អាចជួយអោយអាស៊ានកាត់បន្ថយការពឹងផ្អែកលើទីផ្សារអាមេរិក សហភាពអឺរ៉ុប និងជប៉ុន (Bernadine, 2004) ។ ទីពីរ ប្រទេសចិន មានភាពបត់បែនសំរួលច្រើនជាមួយបណ្តាប្រទេសអាស៊ានថ្មីៗ ដោយផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះពិសេស និងជំនួយអភិវឌ្ឍន៍ ហើយផ្តល់លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (MFN) របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ទៅអោយប្រទេសមិនមែនជាសមាជិកអង្គការ WTO ។ វិធានការបែបនេះ ធ្វើអោយប្រទេសអាស៊ានថ្មីមានភាពងាយស្រួលក្នុងការទាញប្រយោជន៍ពីសេរីភាវូបនីយកម្មជាមួយចិន និងតភ្ជាប់ចន្លោះប្រហោងនៃការអភិវឌ្ឍន៍ក្នុងតំបន់ ។ ទីបី ចិន និងអាស៊ាន អាចធ្វើសេរីភាវូបនីយកម្មលើពាណិជ្ជកម្មកសិកម្មបានច្រើនជាងកិច្ចព្រមព្រៀង និងការសន្យា ដែលធ្វើឡើងដោយសមាជិកអង្គការ WTO ពីព្រោះកសិកម្មតំបន់ត្រជាក់របស់ចិន និងកសិកម្មតំបន់ត្រូពិចរបស់អាស៊ាន មានលក្ខណៈបំពេញគ្នាទៅវិញទៅមក ។ ទីបួន អាស៊ានចាត់ទុកតំបន់ពាណិជ្ជកម្មសេរីនេះថាជាផ្លូវសក្តានុពលមួយ ដើម្បីពន្លឿនការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចក្រោយវិបត្តិ ។ តាមលោកប៊ែណាឌីណូ (២០០៤) បំណងប្រាថ្នារបស់អាស៊ាន គឺចង់ជិះរថភ្លើងសេដ្ឋកិច្ចល្បឿនលឿនរបស់ចិន ក្នុងគោលបំណងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI) ហើយសង្ឃឹមថាអាចបង្វែរទិសទុនវិនិយោគផ្ទាល់ពីបរទេសខ្លះ ដែលកំពុងហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្នុងប្រទេសចិន មកតំបន់អាស៊ីអគ្នេយ៍ ។

ហេតុផលជំរុញឱ្យប្រទេសចិនបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិននេះ មានទាំងលក្ខណៈសេដ្ឋកិច្ច និងនយោបាយ ។ ហេតុផលនយោបាយ គឺថាចិនចង់ចងមិត្តជាមួយប្រទេសជិតខាងនៅប៉ែកខាងត្បូង (Chia, 2004) ។ តំបន់ពាណិជ្ជកម្មសេរីនេះគឺជាផ្នែកមួយនៃដំណើរការកសាងជំនឿទុកចិត្តដើម្បីសំរាលការបារម្ភរបស់អាស៊ាន អំពីការគំរាមកំហែងខាងសេដ្ឋកិច្ចរបស់ចិន ដោយផ្តល់នូវកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាងមុនក្នុងវិស័យជាច្រើន ដូចជាពាណិជ្ជកម្មនិងវិនិយោគទុន កសិកម្ម បច្ចេកវិទ្យា

ព័ត៌មាន និងទូរគមនាគមន៍ ការអភិវឌ្ឍន៍ធនធានមនុស្ស ការអភិវឌ្ឍន៍តំបន់ដងទន្លេមេគង្គ ទេសចរណ៍ និងសន្តិសុខ ។ គោលបំណងសំខាន់មួយទៀតរបស់ចិន គឺនយោបាយភូមិសាស្ត្រៈ ការទប់ទល់នឹងយុទ្ធសាស្ត្ររបស់អាមេរិកប្រឆាំងចិន និងការការពារផ្លូវពាណិជ្ជកម្មនៅអាស៊ីអគ្នេយ៍ ។ ទំនាក់ទំនងសេដ្ឋកិច្ចប្រសើរជាមុនជាមួយអាស៊ាន អាចធ្វើអោយចិនបង្កើនអំណាចខាងនយោបាយភូមិសាស្ត្រ និងអាចទប់ទល់នឹងឥទ្ធិពលរបស់អាមេរិក និងជប៉ុន ។ រីឯហេតុផលសេដ្ឋកិច្ចវិញ គឺចិនចង់ប្រែក្លាយអាស៊ានជាតំបន់ដៃគូ និងប្រភពវត្ថុធាតុដើម ពីព្រោះចិនជាប្រទេសសេដ្ឋកិច្ចឧស្សាហកម្ម និងជាប្រទេសនាំចូលផលិតផលកសិកម្ម (Bernardino, 2004) ។ លោកប៊ែណាឌីណូ ក៏បានអះអាងទៀតថា សមាជិកភាពរបស់ចិន ក្នុងអង្គការ WTO ក្នុងឆ្នាំ២០០១ ហើយសំពាធជាបន្តបន្ទាប់ពីអាមេរិក គឺជាកំលាំងជំរុញអោយចិនបង្កើតសម្ព័ន្ធភាពជាមួយប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ជាពិសេសជាមួយប្រទេសជិតខាងនៅប៉ែកអាស៊ីបូពា៌ ដែលមាន អាស៊ាន ជប៉ុន និងកូរ៉េ តាមរយៈគំនិតផ្តួចផ្តើមអាស៊ាន + ៣ និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ។

## ២.២. ផលចំណេញ និងបញ្ហាប្រឈមខាងសេដ្ឋកិច្ចនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងផ្តល់ប្រយោជន៍សក្តានុពលដល់គ្រប់ប្រទេសជាសមាជិក តាំងពីប្រសិទ្ធភាពសេដ្ឋកិច្ចប្រសើរជាងមុន រហូតដល់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូកាន់តែស្អិទ្ធស្អាលជាងមុនក្នុងវិស័យមិនមែនសេដ្ឋកិច្ច ។ ការលុបបំបាត់ចោលរនាំងពាណិជ្ជកម្មរវាងអាស៊ាន និងចិន អាចបន្ទាបថ្លៃដើម បង្កើនសកម្មភាពពាណិជ្ជកម្មអន្តរតំបន់ និងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ។ តំបន់ពាណិជ្ជកម្មសេរី រំពឹងថា នាំមកនូវឯកទេសនីយកម្មផលិតកម្ម ដោយផ្អែកលើឧត្តមភាពប្រៀបធៀប ។ ការសិក្សារបស់ក្រុមជំនាញការ អាស៊ាន-ចិន លើកិច្ចប្រតិបត្តិការសេដ្ឋកិច្ច បង្ហាញថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងបង្កើនការនាំចេញរបស់អាស៊ាន ទៅចិន ដល់ ១៣ពាន់លានដុល្លារ ឬ ៤៨% និងការនាំចេញរបស់ចិន មក អាស៊ានចំនួន ១០,៦ពាន់លានដុល្លារ ឬ ៥៥,១% ។ ក្នុងចំណោមប្រទេសអាស៊ាន ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ នឹងមានការនាំចេញច្រើនជាងគេបង្អស់ ។ តំបន់ពាណិជ្ជកម្មសេរី ក៏បង្កើនផលិតផលក្នុងស្រុកសរុបរបស់អាស៊ានបាន ០,៩% ឬ ៥,៤ពាន់លានដុល្លារ រីឯផលិតផលក្នុងស្រុកសរុបរបស់ចិនកើនបាន ០,៣% ឬ ២,២ពាន់លានដុល្លារ ។ តារាងកាត់បន្ថយពន្ធគយរបស់កម្មវិធីប្រមូលផលដើមដៃ បង្ហាញថា មានការកើនឡើងយ៉ាងច្រើន រវាងសកម្មភាពពាណិជ្ជកម្មអាស៊ាន-ចិន ។ នៅខែកក្កដា ឆ្នាំ២០០៤ តំលៃផលិតផលនៃកម្មវិធីប្រមូលផលដើមដៃធ្វើពាណិជ្ជកម្ម រវាងអាស៊ាន និងចិន បានឡើងដល់ ១,១១ពាន់លានដុល្លារ ឬខ្ពស់ជាងមួយឆ្នាំមុន ៤២,៣% រីឯការនាំចេញរបស់អាស៊ានទៅចិន មានតំលៃ ០,៦៨ពាន់លានដុល្លារ រឺកើនបាន ៤៩.៨% ធៀបនឹងឆ្នាំមុន (Cordenillo, 2005) ។

ក្រុមជំនាញការ និងលោកប៊ែណាឌីណូ មានទស្សនៈដូចគ្នាថា តំបន់ពាណិជ្ជកម្មសេរី ទំនងជាបង្កើនទិដ្ឋភាពវិនិយោគទុនក្នុងតំបន់ ។ ក្រុមជំនាញការអះអាងថា មិនត្រឹមតែក្រុមហ៊ុនមកពីអាស៊ាន-ចិនប៉ុណ្ណោះទេ ដែលដាក់វិនិយោគទុនក្នុងទីផ្សារសមាហរណកម្មនេះ ប៉ុន្តែមានទាំងក្រុមហ៊ុនមកពីអាមេរិក អឺរ៉ុប និងជប៉ុន ដែលនឹងវាយលុកចូលទីផ្សារនេះ ។ រីឯលោកប៊ែណាឌីណូ បានអះអាងថា ការហូរចូលវិនិយោគផ្ទាល់ពីបរទេស បានធ្លាក់ចុះជាបន្តបន្ទាប់ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ១៩៩៧ ដូច្នេះតំបន់ពាណិជ្ជកម្មសេរីនេះ អាចប្រែក្លាយអាស៊ានជាតំបន់ទាក់ទាញវិនិយោគទុនមួយ ។ ជាក់ស្តែង វិនិយោគផ្ទាល់ពីបរទេស បានកើនឡើងយ៉ាងលឿន បន្ទាប់ពីកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវបានចុះហត្ថលេខា ពោលគឺពីចំនួន ១៣,៨ពាន់លានដុល្លារ ក្នុងឆ្នាំ២០០២ ដល់ ២៥,៦ពាន់លានដុល្លារក្នុងឆ្នាំ២០០៤ ។ នាពេលអនាគត នៅពេលដែលទីផ្សារកាន់តែធំ មានការប្រកួតប្រជែងកាន់តែខ្លាំង និងមានការវិនិយោគទុនកាន់តែច្រើន វិនិយោគិននឹងកាន់តែមានទិន្នាការវិនិយោគទុនក្នុងតំបន់នេះកាន់តែច្រើនដែរ ។

ម្យ៉ាងវិញទៀត តំបន់ពាណិជ្ជកម្មសេរីនេះក៏អាចបង្កអោយមានបញ្ហាប្រឈមជាច្រើនទាំងចំពោះអាស៊ាន និងចិន ។ បើយោងតាមក្រុមជំនាញការអាស៊ាន-ចិន (២០០១) ភាពដូចគ្នាក្នុងរចនាសម្ព័ន្ធឧស្សាហកម្ម រវាងអាស៊ាន និងចិន មានន័យថា ការកាត់បន្ថយ និងលុបបំបាត់របាំងពន្ធគយនិងមិនមែនពន្ធគយ បង្កឱ្យមានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំងនៅលើទីផ្សារក្នុងស្រុករបស់ភាគីទាំងពីរ ។ ជាលទ្ធផល ឧស្សាហកម្មខ្លះអាចរីកចំរើន ហើយឧស្សាហកម្មខ្លះទៀត អាចដួលរលំ ។ ការបិទទ្វារនៃឧស្សាហកម្មទាំងនេះ អាចបង្កអោយមានការខាតបង់រយៈពេលខ្លី ទៅលើកម្មករដែលពុំមានការធ្វើ និងទៅលើសនិទានកម្មរបស់ក្រុមហ៊ុនទាំងនោះ ។ លើសពីនេះ ការលុបបំបាត់ចោលតារាងពន្ធគយ អាចបង្កអោយមានការខាតបង់ចំណូលពន្ធគយ ដូច្នេះអាចបង្កអោយមានភាពលំបាកដល់គោលនយោបាយសារពើពន្ធ ជាពិសេសសំរាប់ប្រទេសពឹងផ្អែកខ្លាំងទៅលើចំណូលពន្ធគយ ។

## ២.៣ លក្ខណៈពិសេសនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

កិច្ចព្រមព្រៀងក្របខ័ណ្ឌគ្របដណ្តប់ពាណិជ្ជកម្មលើទំនិញ សេវាកម្ម និងវិនិយោគទុនដោយផ្តល់ការគាំទ្រ ដល់កម្មវិធីប្រមូលផលដើមដៃ ដើម្បីបង្កើនសេរីភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម និងប្រព្រឹត្តិកម្មអនុគ្រោះ និងពិសេស សំរាប់ប្រទេសសមាជិកអាស៊ានថ្មី ។

គោលបំណងនៃកិច្ចព្រមព្រៀងនេះមាន (១) ពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិនិយោគទុន (២) ធ្វើសេរីភាវូបនីយកម្មជាលំដាប់ និងជំរុញសកម្មភាពពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម ព្រមទាំងបង្កើតរបបវិនិយោគទុនមួយប្រកបដោយតម្លាភាព សេរីភាព និងការសំរបសំរួលល្អ (៣) រិះរកវិស័យថ្មីៗ និងបង្កើតវិធានការសមរម្យសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចស្និទ្ធស្នាលជាងមុន និង (៤) សំរបសំរួលសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសអាស៊ានថ្មីអោយមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងលុបបំបាត់គំលាតខាងការអភិវឌ្ឍន៍ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កិច្ចព្រមព្រៀងក្របខណ្ឌនេះបានបញ្ជាក់ពីវិធានការមួយចំនួនដែលអាស៊ាន និងចិនគួរប្រកាន់យកៈ

- លុបបំបាត់រនាំងពន្ធគយ និងមិនមែនពន្ធគយទាំងស្រុងក្នុងរាល់សកម្មភាពពាណិជ្ជកម្មលើទំនិញសំខាន់
- ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មជាលំដាប់លើសេវាកម្ម
- បង្កើតអោយមានរបបវិនិយោគទុនមានលក្ខណៈបើកចំហ និងមានការប្រកួតប្រជែង
- ផ្តល់ប្រព្រឹត្តិកម្មពិសេស និងអនុគ្រោះ និងភាពបត់បែនដល់សមាជិកអាស៊ានថ្មី
- ផ្តល់ភាពបត់បែនដើម្បីដោះស្រាយវិស័យមានភាពរសើបក្នុងពាណិជ្ជកម្មលើទំនិញ សេវាកម្ម និងវិនិយោគទុនសំរាប់ការចរចាតំបន់ពាណិជ្ជកម្មសេរីនេះ
- បង្កើតវិធានការសំរបសំរួលខាងពាណិជ្ជកម្ម និងវិនិយោគទុនដ៏មានប្រសិទ្ធភាព ដូចជាការធ្វើឱ្យសាមញ្ញនូវនិតិវិធីពន្ធគយ និងការបង្កើតកិច្ចព្រមព្រៀងទទួលស្គាល់រួមគ្នា ។
- ពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច លើវិស័យដែលជួយបំពេញដល់ការលើកស្ទួយសកម្មភាពពាណិជ្ជកម្ម និងវិនិយោគទុន
- បង្កើតផែនការ និងកម្មវិធីសកម្មភាព ដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការលើវិស័យបានព្រមព្រៀង ហើយនិងយន្តការសមស្របដើម្បីអនុវត្តកិច្ចព្រមព្រៀង ។

## ២.៣.១ ពាណិជ្ជកម្មទំនិញ

អាស៊ាន និងចិន បានយល់ព្រមកាត់បន្ថយតារាងពន្ធគយ រាល់ទំនិញទាំងអស់ដែលមិនរាប់បញ្ចូលក្នុងកម្មវិធីប្រមូលផលដើមដៃ ។ នៅដើមឆ្នាំ២០០៣ ការចរចាលើសេរីភាវូបនីយកម្មពាណិជ្ជកម្មលើទំនិញ ដែលមានទំរង់នៃការកាត់បន្ថយ រឺលុបបំបាត់ពន្ធគយ វិធានស្តីពីប្រភពដើម វិធានការមិនមែនពន្ធគយ វិធានការសុវត្ថិភាព ដែលផ្អែកលើគោលការណ៍នៃកិច្ចព្រមព្រៀងទូទៅស្តីអំពីតារាងពន្ធគយ និងពាណិជ្ជកម្ម (GATT) នីតិវិធីនៃការឧបត្ថម្ភធន និងវិធានការប្រឆាំងការលក់ទាបជាងថ្លៃដើម ។ កិច្ចព្រមព្រៀងលើពាណិជ្ជកម្មទំនិញរបស់កម្មវិធីប្រមូលផលដើមដៃ ត្រូវបានចុះហត្ថលេខានៅក្នុងកិច្ចប្រជុំកំពូលអាស៊ានទី ១០ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ ។

មុខទំនិញដែលត្រូវយកមកកាត់បន្ថយ រឺលុបបំបាត់ពន្ធគយ រួមមាន មុខទំនិញទាំងអស់ដែលមិនស្ថិតក្នុងកម្មវិធីប្រមូលផលដើមដៃ ហើយមុខទំនិញទាំងនេះត្រូវបានបែងចែកជាពីរប្រភេទ:

- គំរោងធម្មតា (normal track): ផលិតផលរាប់បញ្ចូលក្នុងគំរោងធម្មតា ត្រូវកាត់បន្ថយ រឺ លុបបំបាត់ទាំងស្រុងនូវអត្រាពន្ធគយ MFN ស្របនឹងអត្រា និងកាលវិភាគដែលបានកំនត់ ក្នុងកំឡុងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ សំរាប់អាស៊ាន ៦ និងចិន និងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ដល់ឆ្នាំ២០១៥ សំរាប់សមាជិកអាស៊ានថ្មី[១] ។ អត្រាពន្ធគយដែលត្រូវបានកាត់បន្ថយ ប៉ុន្តែពុំទាន់បានលុបបំបាត់ នឹងត្រូវលុបបំបាត់ជាបណ្តើរៗអោយបានទាំងស្រុងក្នុងរយៈពេលមួយមានការយល់ព្រមទាំងសងខាង ។
- គំរោងរសើប (sensitive track): ផលិតផលរាប់បញ្ចូលក្នុងគំរោងមានភាពរសើបត្រូវកាត់បន្ថយអត្រាពន្ធគយ MFN មកត្រឹមអត្រា និងរយៈពេលមួយមានការយល់ព្រមទាំងសងខាង ។ ចំនួនផលិតផលក្នុងគំរោងនេះ មិនត្រូវអោយមានលើសពី ៤០០ផលិតផល គិតក្នុងប្រព័ន្ធសំរបសំរួល (harmonised system) កំរិត ៦ខ្ទង់ និង ១០% នៃតំលៃទំនិញនាំចូល[២] សំរាប់ប្រទេសអាស៊ាន ៦ និងប្រទេសចិន និងមិនអោយលើសពី ៥០០ផលិតផល សំរាប់ប្រទេសអាស៊ានថ្មី ។

## ២.៣.២ ពាណិជ្ជកម្មសេវាកម្ម

អាស៊ាន និងចិន ក៏បានយល់ព្រមចរចាគ្នាពីសេរីភាវូបនីយកម្មជាលំដាប់លើពាណិជ្ជកម្មសេវាកម្ម ដោយមានការគ្របដណ្តប់ទូលំទូលាយជាងមុន ។ ការចរចានេះ បានចាប់ផ្តើមនៅឆ្នាំ២០០៣ និងគ្រោងបញ្ចប់អោយបានឆាប់រហ័ស ។ ការចរចានេះមានទិសដៅលុបបំបាត់ទាំងស្រុងនូវរាល់ការរើសអើង ពង្រីកទំហំនិងជំរៅនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការបន្ថែមទៀតលើវិស័យសេវាកម្ម ដើម្បីបង្កើនប្រសិទ្ធភាព និងសមត្ថភាពប្រកួតប្រជែង ព្រមទាំងធ្វើអោយមានភាពចំរុះផ្នែកសេវាកម្មផ្គត់ផ្គង់ និងចែកចាយ ។

## ២.៣.៣. វិនិយោគទុន

ដើម្បីជំរុញការវិនិយោគ និងបង្កើតរបបវិនិយោគទុនមួយមានលក្ខណៈសេរី សំរបសំរួល តម្លាភាព និងការប្រកួតប្រជែងភាគីទាំងអស់បានយល់ព្រម: (១) ចរចាធ្វើសេរីភាវូបនីយកម្មជាលំដាប់នូវរបបវិនិយោគទុន (២) ពង្រឹងកិច្ចសហប្រតិបត្តិការលើ

---

(១) ព័ត៌មានលំអិតពីទិន្នន័យ និងអត្រាជាក់លាក់ សូមមើលឧបសម្ព័ន្ធទី ១ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មលើទំនិញ នៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងចិន តាម http: //www.aseansec.org

(២) ផ្អែកលើស្ថិតិពាណិជ្ជកម្មឆ្នាំ២០០១

ការវិនិយោគទុនសំរបសំរួលវិនិយោគទុន និងបង្កើនតម្លាភាពនៃច្បាប់ និងបទប្បញ្ញត្តិវិនិយោគទុន និង (៣) ផ្តល់ការការពារដល់វិនិយោគទុន ។

អាស៊ាន និងចិន ក៏បានយល់ព្រមពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាព ៥ គឺកសិកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគនាគមន៍ ការអភិវឌ្ឍន៍ធនធានមនុស្ស វិនិយោគទុន និងការអភិវឌ្ឍន៍តំបន់អាងទន្លេមេគង្គ ។ នៅមានកម្មវិធីកសាងសមត្ថភាព និងជំនួយបច្ចេកទេស ជាពិសេសសំរាប់ប្រទេសអាស៊ានថ្មី ដើម្បីអោយប្រទេសទាំងនោះ អាចកែសំរួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និងពង្រីកសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគទុនជាមួយចិន ។

### ២.៣.៤. កម្មវិធីប្រមូលផលដើមដៃ

គេដាក់បញ្ចូលកម្មវិធីប្រមូលផលដើមដៃទៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដើម្បីបង្កើនល្បឿននៃការកាត់បន្ថយ និងលុបបំបាត់តារាងពន្ធគយលើពាណិជ្ជកម្មទំនិញ នៅក្នុងជំពូកទី១ ដល់ ទី៨ នៃប្រព័ន្ធសំរបសំរួលខ្ទង់ទី ៨/៩ ដែលរួមមាន:

១. សត្វរស់

២. សាច់ និងគ្រឿងក្នុងអាចហូបបាន

៣. ត្រី

៤. ផលិតផលពីទឹកដោះគោ

៥. ផលិតផលធ្វើចេញពីសត្វផ្សេងទៀត

៦. ដើមរុក្ខជាតិរស់

៧. បន្លែអាចហូបបាន

៨. ផ្លែឈើ និងគ្រាប់ផ្លែឈើអាចហូបបាន

នៅមានការបែងចែកជាបីប្រភេទចំពោះរាល់ផលិតផលរាប់បញ្ចូលក្នុងកម្មវិធីប្រមូលផលដើមដៃ សំរាប់ការកាត់បន្ថយ និងលុបបំបាត់តារាងពន្ធគយ:

ប្រភេទ ១: សំរាប់ប្រទេសអាស៊ាន ៦ និងចិន ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងខ្ពស់ជាង ១៥% ។ សំរាប់ប្រទេសអាស៊ានថ្មី ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងស្មើ ឬខ្ពស់ជាង ៣០% ។

ប្រភេទ ២: សំរាប់ប្រទេសអាស៊ាន ៦ និងចិន ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងចន្លោះពី ៥% ទៅ ១៥% ។ សំរាប់ប្រទេសអាស៊ានថ្មី ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងចន្លោះពី ១៥% ទៅ ៣០% ។

ប្រភេទ ៣: សំរាប់ប្រទេសអាស៊ាន ៦ និងចិន ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងទាបជាង ៥% ។ សំរាប់ប្រទេសអាស៊ានថ្មី ប្រភេទនេះសំដៅលើផលិតផលមានអត្រាពន្ធគយ MFN ជាក់ស្តែងទាបជាង ១៥% ។

កម្មវិធីប្រមូលផលដើមដៃ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤ ដែលមានពេលវេលា និងកាលវិភាគធ្វើសេរីភាវូបនីយកម្មដូចខាងក្រោម:

### *តារាង ១: ចិន និង អាស៊ាន ៦*

| ប្រភេទផលិតផល | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ |
|---|---|---|---|
| ១ | ១0% | ៥% | 0% |
| ២ | ៥% | 0% | 0% |
| ៣ | 0% | 0% | 0% |

### *តារាង ២: ប្រទេសអាស៊ានថ្មី*

*ប្រភេទទី ១:*

| ប្រទេស | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ | មិនយូរជាងថ្ងៃ ១ មករា ២០០៧ | មិនយូរជាងថ្ងៃ ១ មករា ២០០៨ | មិនយូរជាងថ្ងៃ ១ មករា ២០០៩ | មិនយូរជាងថ្ងៃ ១ មករា ២០១០ |
|---|---|---|---|---|---|---|---|
| វៀតណាម | ២0% | ១៥% | ១0% | ៥% | 0% | 0% | 0% |
| ឡាវ និង ភូមា | - | - | ២0% | ១៤% | ៨% | 0% | 0% |
| កម្ពុជា | - | - | ២0% | ១៥% | ១0% | ៥% | 0% |

*ប្រភេទទី ២:*

| ប្រទេស | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ | មិនយូរជាងថ្ងៃ ១ មករា ២០០៧ | មិនយូរជាងថ្ងៃ ១ មករា ២០០៨ | មិនយូរជាងថ្ងៃ ១ មករា ២០០៩ | មិនយូរជាងថ្ងៃ ១ មករា ២០១០ |
|---|---|---|---|---|---|---|---|
| វៀតណាម | ១0% | ១0% | ៥% | ៥% | 0% | 0% | 0% |
| ឡាវនិងភូមា | - | - | ១0% | ១0% | ៥% | 0% | 0% |
| កម្ពុជា | - | - | ១0% | ១0% | ៥% | ៥% | 0% |

*ប្រភេទទី ៣:*

| ប្រទេស | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ | មិនយូរជាងថ្ងៃ ១ មករា ២០០៧ | មិនយូរជាងថ្ងៃ ១ មករា ២០០៨ | មិនយូរជាងថ្ងៃ ១ មករា ២០០៩ | មិនយូរជាងថ្ងៃ ១ មករា ២០១០ |
|---|---|---|---|---|---|---|---|
| វៀតណាម | ៥% | ៥% | 0-៥% | 0-៥% | 0% | 0% | 0% |
| ឡាវនិងភូមា | - | - | ៥% | ៥% | 0-៥% | 0% | 0% |
| កម្ពុជា | - | - | ៥% | ៥% | 0-៥% | 0-៥% | 0% |

កម្មវិធីប្រមូលផលដើមដៃ ក៏អនុញ្ញាតអោយប្រទេសសមាជិក ដកចេញផលិតផលរសើប១មួយចំនួន ពីការធ្វើសេរីភាវូបនីយកម្ម ។ ភាគីណាដែលដកចេញនូវ សមាជិកអាស៊ានផ្សេងទៀត រឺ ចិន ចេញពីការអនុគ្រោះពន្ធគយ តាមរយៈបញ្ជីដកចេញ នឹងពុំបានទទួលការអនុគ្រោះពន្ធគយលើផលិតផលមកពីសមាជិកអាស៊ានផ្សេងទៀត រឺ ពីចិនឡើយ ។ ប្រទេសសិង្ហបូរី ប្រ៊ុយណេ ថៃ ឥណ្ឌូនេស៊ី និងភូមា ពុំមានផលិតផលដែលមិនត្រូវរាប់បញ្ចូលឡើយ ។ ដោយឡែក កម្ពុជា ឡាវ ម៉ាឡេស៊ី ហ្វីលីពីន និងវៀតណាម មានដកចេញផលិតផលមួយចំនួន ។ ប្រទេសកម្ពុជា ដកចេញផលិតផល ៣០មុខ ពីការកាត់បន្ថយពន្ធគយ ដូចជា ជ្រូករស់ ត្រីរស់ ប៉េងប៉ោះ ខ្ទឹមបារាំង ខ្ទឹមស ឆៃថាវ ផ្កាខាត់ណា ខាត់ណា ស្ពៃក្តោប សាឡាដ ការ៉ុត ស្ពៃមើម ដូងម្នាស់ ស្វាយ ក្រូច ឪឡឹក ត្រសក់ស្រូវ និងម្សៅ ។

សរុបមក ទោះបីហេតុផលនៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន មានលក្ខណៈសេដ្ឋកិច្ចផង និងនយោបាយផងក្តី ប៉ុន្តែផលចំណេញសេដ្ឋកិច្ចរំពឹងទុក គឺជាកត្តាជំរុញសំខាន់នៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីនេះ ។

# ជំពូកទី ៣. ផលប៉ះពាល់សក្តានុពលនៃ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងកម្មវិធី ប្រមូលផលដើមដៃមកលើប្រទេសកម្ពុជា

ជំពូកនេះពិភាក្សាពីផលប៉ះពាល់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងកម្មវិធីប្រមូលផលដើមដៃ លើប្រទេសកម្ពុជាជារួម និងលើវិស័យកសិកម្មជាពិសេស ។ ដំបូងអត្ថបទនេះរំលឹកឡើងវិញពីការវិវត្តន៍ថ្មីៗនៃទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងចិន ដោយផ្តោតការយកចិត្តទុកដាក់លើពាណិជ្ជកម្ម និងវិនិយោគ ។ រចនាសម្ព័ន្ធពាណិជ្ជកម្មនៃផលិតផលក្នុងកម្មវិធីប្រមូលផលដើមដៃរវាងកម្ពុជា និងចិនក្នុងពេលថ្មីៗនេះ ក៏ត្រូវបានពិនិត្យមើលក្នុងជំពូកនេះដែរ ។ បន្ទាប់មក មានការពិនិត្យមើលពីឱកាស និងបញ្ហាប្រឈមនៃតំបន់ពាណិជ្ជកម្មសេរី ចំពោះប្រទេសកម្ពុជា ។ ជំពូកនេះ ក៏វាយតំលៃពីផលប៉ះពាល់សក្តានុពលនៃកម្មវិធីប្រមូលផលដើមដៃ លើវិស័យកសិកម្ម ក្នុងន័យជាឱកាសនាំចេញ និងការគំរាមកំហែងនៃផលិតផលនាំចូលដល់ផលិតករក្នុងស្រុក លើនិន្នាការ និងរចនាសម្ព័ន្ធពាណិជ្ជកម្មរវាងកម្ពុជានិងចិន ដោយផ្អែកលើរចនាសម្ព័ន្ធពាណិជ្ជកម្មរវាងចិន និងថៃនិងវៀតណាម ។ ផ្នែកចុងក្រោយនៃជំពូកបី និយាយអំពីផលប៉ះពាល់មួយចំនួននៃកម្មវិធីនេះ លើភាពក្រីក្រ ដោយពិនិត្យលើការចូលរួមរបស់កសិករតូចតាច និងអ្នកក្រីក្រ ក្នុងសេរីភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម ។

## ៣.១. ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និង ចិន

ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និង ចិន មានការរីកចំរើនគួរអោយកត់សំគាល់ចាប់តាំងពីទសវត្សរ៍ ១៩៩០ ។ នៅមុនកិច្ចព្រមព្រៀងក្របខ័ណ្ឌ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំរុញ និងការពារវិនិយោគ ជាមួយចិនក្នុងខែកក្កដា ឆ្នាំ១៩៩៦ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីក្នុងខែកក្កដា ១៩៩៧ ។ កិច្ចព្រមព្រៀងទាំងនេះ បានបង្កើតជាមូលដ្ឋានសំរាប់សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគទៅវិញទៅមក ។ ចិន គឺជាប្រភពវិនិយោគទុនផ្ទាល់ពីបរទេសធំជាងគេក្នុងលំដាប់ទីបួនរបស់កម្ពុជាក្នុងឆ្នាំ១៩៩៥-២០០៤ ដោយបានវិនិយោគទុន ៣៩៥លានដុល្លារ ឬ ៩% នៃវិនិយោគទុនផ្ទាល់ពីបរទេសសរុប (តារាង A.2 ក្នុងឧបសម្ព័ន្ធស្ថិតិ) ។ ចិនជាដៃគូពាណិជ្ជកម្មធំជាងគេទី ៧ (ប្រាំពីរ) របស់កម្ពុជាក្នុងឆ្នាំ១៩៩៥ និងធំជាងគេទីបួនក្នុងឆ្នាំ២០០៣ ។ ពាណិជ្ជកម្មកម្ពុជា-ចិន បានកើនក្នុងអត្រាមធ្យមប្រចាំឆ្នាំ ២៣% កំឡុងឆ្នាំ១៩៩៥-២០០១ និង ៦២% ក្នុងឆ្នាំ២០០២-០៥ ។ ក្នុងឆ្នាំ២០០៥ ការនាំចេញរបស់កម្ពុជាទៅចិនមាន ២៧,៣លានដុល្លារ និងការនាំចូលពីចិនវិញចំនួន ៥៣៦,១១លានដុល្លារ ។

តារាង ៣.១ និង ៣.២ បង្ហាញថា កម្ពុជានាំចេញនូវផលិតផលកសិកម្ម និងផលិតផលធនធានធម្មជាតិ ហើយនាំចូលមកវិញនូវផលិតផលឧស្សាហកម្មជាច្រើនប្រភេទ ដូចជា វាយនភណ្ឌនិងសំលៀកបំពាក់ ដែកថែប សេរ៉ាមិក ឧបករណ៍អគ្គិសនី និងអេឡិចតូនិក ម្ហូបអាហារ និងយានជំនិះ ។ ផលិតផលនាំចេញធំជាងគេរបស់កម្ពុជា ទៅកាន់ចិនកំឡុងឆ្នាំ២០០០-០៥ គឺឈើ និងផលិតផលធ្វើពីឈើដែលមានតំលៃ ១៣២លានដុល្លារ ឬច្រើនជាងពាក់កណ្តាលនៃការនាំចេញសរុបទៅកាន់ចិន ។ ផលិតផលនាំចេញសំខាន់ៗផ្សេងទៀតរួមមាន កប្បាស កៅស៊ូ ត្រី បង្គា និងសត្វរស់ ។ រីឯការនាំចូលរបស់កម្ពុជាពីចិន បានកើនឡើងយ៉ាងឆាប់រហ័សពី ១៦៤,១លានដុល្លារ ក្នុងឆ្នាំ២០០០ ដល់ ៥៣៦,១១លានដុល្លារក្នុងឆ្នាំ២០០៥ ។ ការនាំចូលវាយនភណ្ឌ និង

សំលៀកបំពាក់មានចំនួនសរុប ១.២១០លានដុល្លារ ក្នុងកំឡុងឆ្នាំ២000-0៥ រឺ ៦៣%នៃការនាំចូលសរុបពីចិន ។ កំណើនដ៏ច្រើននៃការនាំចូលផលិតផលនេះ បណ្តាលមកពីកំណើនតំរូវការធាតុចូលសំរាប់ផលិតកម្មសំលៀកបំពាក់ដែលកើនឡើងជាប់រហូតក្នុងប្រទេសកម្ពុជា ។ ការនាំចូលធំទីពីរ គឺឧបករណ៏អគ្គិសនី និងគ្រឿងម៉ាស៊ីន ដែលមានតំលៃ ១៩៤,៦២លានដុល្លារ កំឡុងឆ្នាំ២000-0៥ ឬ ១០% នៃការនាំចូលសរុបពីចិន ។ ផលិតផលនាំចូលសំខាន់ៗដទៃទៀតរួមមាន សាច់ ត្រី និងផលិតផលគ្រឿងសមុទ្រ ដែកនិងដែកថែប គ្រឿងធ្វើពីដែកនិងដែកថែប ផលិតផលសេរ៉ាមិក និងយានយន្ត ។

***តារាង ៣.១: ការនាំចេញរបស់កម្ពុជាទៅកាន់ចិនឆ្នាំ២000-២00៥ (លានដុល្លារ)***

| លេខកូដ HS | វាយមុខផលិតផល | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| | **ផលិតផលសរុប** | **59.49** | **34.8** | **24.55** | **26.17** | **29.56** | **27.3** |
| 44 | ឈើនិងផលិតផលធ្វើពីឈើ | 50.27 | 27.03 | 15.12 | 13.64 | 15.06 | 11.1 |
| 52 | កប្បាស | - | 0.44 | 0.1 | 3.15 | 8.85 | 7.56 |
| 40 | កៅស៊ូនិងផលិតផលធ្វើពីកៅស៊ូ | 5.41 | 5.71 | 7.48 | 7.68 | 2.53 | 3.13 |
| 03 | ត្រី បង្គា និងសិប្បិសត្វ | 1.07 | 0.93 | 1.28 | 1.13 | 1.28 | 0.73 |
| 62 | សំលៀកបំពាក់និងបំណែកសំរាប់បន្ថែម | 2.5 | 0.08 | 0.04 | 0.04 | 0.68 | 1.79 |
| 33 | ប្រេងរុក្ខជាតិ ទឹកអប់ គ្រឿងក្រអូប | - | - | - | 0.09 | 0.06 | 1.08 |
| 01 | សត្វរស់ | 0.21 | 0.24 | 0.32 | 0.06 | 0.04 | 0.24 |

*ប្រភព:* *Global Trade Atlas*

ពាណិជ្ជកម្មកម្ពុជា-ចិនលើផលិតផលក្នុងកម្មវិធីប្រមូលផលដើមដៃ ដូចដែលបានបង្ហាញក្នុងតារាងទី៣ ពុំមានចំនួនច្រើនទេ គឺមានត្រឹមតែ 0,៣៣% ក្នុងកំឡុងឆ្នាំ២000-0៥ ។ ក្នុងកំឡុងពេលដូចគ្នានេះដែរ ការនាំចេញរបស់កម្ពុជានូវផលិតផលក្នុងកម្មវិធីប្រមូលផលដើមដៃ មានចំនួនប្រហែលជា ២%នៃការនាំចេញសរុបទៅចិន ។ ត្រីរស់ គឺជាផលិតផលនាំចេញធំជាងគេទីមួយក្នុងកំឡុងឆ្នាំ២000-0៥ ដែលមានតំលៃ ៣,៩៩លានដុល្លារ បន្ទាប់មកមាន បង្គា សត្វរស់ និងផ្សិត ដែលមានតំលៃសរុបរៀងគ្នាចំនួន ២,៣៦លានដុល្លារ ១,១២លានដុល្លារ និង ២៩.៨៩៤ដុល្លារ ។ ការនាំចូលរបស់កម្ពុជានូវផលិតផលក្នុងកម្មវិធីនេះមានចំនួន ៣,៤៣លានដុល្លារ ក្នុងអំឡុងឆ្នាំ២000-0៥ ឬ 0,១៨% នៃការនាំចូលសរុបពីចិន ។ ក្នុងពេលដូចគ្នានេះ ខ្ទឹមស គឺជាផលិតផលនាំចូលធំទីមួយ មានតំលៃ ១,៣៧លានដុល្លារ បន្ទាប់មកមានផ្លែប៉ោម និងផ្សិត ដែលមានតំលៃរៀងគ្នា ៩៤៦.៦៣៥ដុល្លារ និង ៥៤៧.៥២៥ដុល្លារ ។ ផលិតផលនាំចូលផ្សេងទៀត រួមមាន ផ្លែព័រ និងគ្រឿនស៏ សណ្តែកក្រហម ទឹកឃ្មុំ និងត្រី ។

*តារាង ៣.២ : ការនាំចូលរបស់កម្ពុជាពីចិនឆ្នាំ២០០០-២០០៥ (លានដុល្លារ)*

| លេខកូដ HS | វាយមុខផលិតផល | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| **1-99** | **ផលិតផលសរុប** | **164.1** | **205.58** | **251.6** | **294.59** | **452.33** | **536.11** |
| ***50-63*** | ***វាយនភណ្ឌនិងសំលៀកបំពាក់*** | ***78.54*** | ***109.94*** | ***154.11*** | ***205.77*** | ***297.45*** | ***364.74*** |
| 52 | កប្បាស | 32.68 | 49.85 | 62.15 | 79.24 | 118.27 | 127.232 |
| 55 | សរសៃអំបោះសិប្បនិម្មិត | 8.5 | 11.03 | 17.32 | 15.88 | 32.17 | 38.51 |
| 54 | សរសៃផ្លាស្ទិកសំយោគ | 4.27 | 6.15 | 8.12 | 12.64 | 20.42 | 24.44 |
| 58 | ក្រណាត់តម្បាញពិសេស | 3.27 | 3.31 | 10.82 | 11.7 | 21.08 | 20.17 |
| 60 | ផលិតផលបានមកពីការចាក់ដោយម្ជុល | 21.67 | 30.38 | 44.44 | 70.85 | 85.98 | 123.54 |
| 61 | សំលៀកបំពាក់និងបំណែកសំរាប់បន្ថែម ដែលបានមកពីចាក់ដោយម្ជុល | 6.38 | 6.82 | 6.6 | 9.37 | 8.97 | 20.84 |
| ***84-85*** | ***ឧបករណ៍អគ្គិសនី និងគ្រឿងម៉ាស៊ីន*** | ***25.08*** | ***26.42*** | ***30.74*** | ***22.22*** | ***37.55*** | ***52.61*** |
| 84 | ម៉ាស៊ីន និងបរិធានមេកានិក | 11.13 | 11.79 | 20.12 | 14.32 | 22.02 | 34.28 |
| 85 | សំភារៈអគ្គិសនីនិងអេឡិចត្រូនិក | 13.95 | 14.63 | 10.62 | 7.9 | 15.527 | 18.33 |
| | **ផលិតផលផ្សេងទៀត** | | | | | | |
| 16 | សាច់ ត្រី និងគ្រឿងសមុទ្រដែល រៀបចំហើយ | - | - | - | - | 19.67 | 14.31 |
| 72 | ដែក និងដែកថែប | 12.01 | 8.48 | 6.27 | 9.01 | 14.03 | 9.84 |
| 69 | ផលិតផលសេរ៉ាមិក | 3.26 | 4.87 | 7.52 | 10.34 | 13.88 | 22.53 |
| 73 | ឧបករណ៍ធ្វើពីដែក ឬដែកថែប | 4.18 | 7.35 | 13.45 | 0.95 | 9.13 | 5.85 |
| 87 | យានយន្តក្រៅពីរថភ្លើង រថអគ្គិសនី | 3.61 | 3.25 | 3.27 | 10.78 | 6.71 | 7.38 |

*ប្រភព: Global Trade Atlas*

*តារាង ៣.៣ៈ ពាណិជ្ជកម្មកម្ពុជាជាមួយចិន លើផលិតផលក្នុងកម្មវិធីប្រមូលផលដើមដៃឆ្នាំ២០០០-០៥ (លានដុល្លារ)*

| លេខកូដ HS | រាយមុខផលិតផល | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| **ការនាំចេញ** | | | | | | | |
| 030623 | បង្គារ | 609,528 | 90,916 | 211,676 | 426,802 | 720,801 | 301,581 |
| 030199 | ត្រីរស់ | 463,849 | 835,612 | 1,062.945 | 682,791 | 520,214 | 420,178 |
| 010600 | សត្វរស់ | 209,515 | 242,728 | 317,217 | 63,748 | 40,000 | 243,500 |
| 071239 | ផ្សិតក្រៀម | - | - | - | - | - | 29.894 |
| **ការនាំចូល** | | | | | | | |
| 070320 | ខ្ទឹមស ស្រស់ រឺស្ងួត | - | 48,320 | 78,680 | 526,466 | 720,278 | - |
| 070310 | ខ្ទឹមបារាំង និងខ្ទឹមក្រហម | - | 2,601 | - | - | 15,306 | - |
| 080810 | ផ្លែប៉ោមស្រស់ | 93,407 | 23,077 | 32,257 | 47,834 | 287,098 | 556,369 |
| 080820 | ផ្លែព័រ និងគ្វីនស៍ស្រស់ | 10,065 | 21,548 | 29,366 | 4,620 | 130,192 | 143,349 |
| 071239 | ផ្សិតក្រៀម | - | - | - | 42,187 | 279,078 | 226,260 |
| 071332 | សណ្តែកប្រហមតូច ស្ងួត បកសំបករួច | - | - | - | 16,588 | 32,890 | - |
| 040900 | ទឹកឃ្មុំធម្មជាតិ | - | - | - | 12,588 | 3,147 | 1,593 |

*ប្រភពៈ Global Trade Atlas*

## ៣.២. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនៈ ឱកាសនិងបញ្ហាប្រឈមសំរាប់កម្ពុជា

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ទំនងជាបង្កើតទាំងឱកាស និងបញ្ហាប្រឈមដល់ប្រទេសកម្ពុជា ។ ឱកាសមានទាំងឱកាសសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច រីឯបញ្ហាប្រឈមមានការបារម្ភពីផលប៉ះពាល់សក្តានុពល អវិជ្ជមានទៅលើកសិករ និងផលិតករក្នុងស្រុក កំណែទំរង់ស្ថាប័ននិងគោលនយោបាយ ដើម្បីទាញប្រយោជន៍បានច្រើនបំផុតពីគំរោងសេរីភាវូបនីយកម្មពាណិជ្ជកម្មនេះ ។

### *៣.២.១. ឱកាស*

តំបន់ពាណិជ្ជកម្មសេរី នឹងធ្វើអោយការនាំចេញរបស់កម្ពុជាអាចឈានចូលក្នុងទីផ្សារដ៏មានសន្ទុះ និងមានកំណើនឆាប់រហ័សរបស់ចិន ។ ការទទួលបានទីផ្សារនេះ មានសារៈសំខាន់ណាស់សំរាប់ប្រទេសតូចតាចដូចជាកម្ពុជា ដែលទីផ្សារក្នុងស្រុករបស់ខ្លួនមិនធំ ។ ការពង្រឹងលទ្ធភាពទទួលបានទីផ្សារ ធ្វើអោយសហគ្រាសក្នុងស្រុកផលិតបានប្រសិទ្ធភាពខ្ពស់ជាងមុន ។

ទីពីរ ការលុបបំបាត់ចោលរនាំងពន្ធគយ និងមិនមែនពន្ធគយ នឹងជួយសំរួលដល់លំហូរពាណិជ្ជកម្ម ហើយជំរុញអោយមានឯកទេសនីយកម្មដោយផ្អែកលើលក្ខណៈធម្មជាតិនៃកត្តាផលិតកម្ម ។ យោងតាមស្ថិតិពាណិជ្ជកម្ម កម្ពុជានាំចេញផលិតផលកសិកម្ម និងផលិតផលធនធានធម្មជាតិ ដូចជា ឈើ កៅស៊ូ សត្វរស់ ត្រី បង្គារ ហើយនាំចូលពីចិនមកវិញនូវផលិតផលឧស្សាហកម្ម ដូចជា ដែកនិងដែកថែប សេរ៉ាមិក ឧបករណ៍អគ្គិសនីនិងអេឡិចត្រូនិក ម្ហូបអាហារ និងយានយន្ត ។ រចនាសម្ព័ន្ធ

ពាណិជ្ជកម្មនេះ បង្ហាញពីការបំពេញគ្នាយ៉ាងខ្ពស់រវាងការនាំចេញរបស់កម្ពុជា និងចិន ដែលជាកត្តាអាចធ្វើអោយមានឯកទេសនីយកម្មកាន់តែខ្ពស់ និងទទួលផលចំណេញច្រើននៅពេលមានសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។

ទីបី ក្រៅពីការកាត់បន្ថយនិងលុបបំបាត់រនាំងពន្ធគយ និងមិនមែនពន្ធគយ កិច្ចព្រមព្រៀងក្របខ័ណ្ឌ ក៏មានចែងពីរបបវិនិយោគទុន ដែលមានការបើកចំហ តម្លាភាព និងការប្រកួតប្រជែងជាងមុន ។ រឿងនេះនឹង ជួយសំរួលដល់លំហូរវិនិយោគទុនដើម្បីរិះរកឱកាសសេដ្ឋកិច្ចស្របទៅនឹងសមត្ថភាពប្រកួតប្រជែង និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជា ។ កម្ពុជាមានឧត្តមភាពប្រកួតប្រជែងជាសក្តានុពលក្នុងវិស័យកសិកម្ម ដោយសារកម្ពុជា មានដីដាំដុះច្រើនលើសលុបតែខ្វះជំនាញ (Toshiyasu, Chan and Long, 1998)[៣] ។ ប៉ុន្តែវិនិយោគទុន ក្នុងវិស័យនេះមានតែ ៥% នៃវិនិយោគទុនសរុបប៉ុណ្ណោះ (សូមមើលតារាង A.1 ក្នុងឧបសម្ព័ន្ធស្ថិតិ) ។ កម្មវិធីប្រមូលផលដើមដៃ អាចបង្កើនវិនិយោគទុនលើវិស័យកសិកម្ម ដើម្បីទាញប្រយោជន៍ពីលទ្ធភាពទទួលបានទីផ្សារ ។ ក្រៅពីនេះ ក៏លទ្ធភាពច្រើនដែរដែលវិស័យត្រូវការប្រើប្រាស់កំលាំងពលកម្ម និងវិស័យឧស្សាហកម្មមូលដ្ឋានក្នុងប្រទេសអាស៊ាន ៦ និងចិន នឹងអាចបំលាស់ទីទៅប្រទេសដែលមានការអភិវឌ្ឍន៍ទាបដូចប្រទេសកម្ពុជា ពីព្រោះប្រទេសទាំងនោះបានអភិវឌ្ឍ និងផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ខ្លួនឆ្ពោះទៅខាងសេដ្ឋកិច្ចប្រើដំណេះដឹង និងបច្ចេកវិទ្យាច្រើន ។ ការផ្លាស់ប្តូរតាមលំនាំនេះ បានកើតឡើងក្នុងតំបន់អាស៊ីបូពា ដោយឧស្សាហកម្មដូចជា វាយនភណ្ឌ កម្មន្តសាល និងរថយន្ត បានផ្លាស់ទីពីជប៉ុនទៅ តៃវ៉ាន់ និងហុងកុង បន្ទាប់មកទៅ ថៃ ម៉ាឡេស៊ី និង ចិន ។

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នឹងបង្កើតឱកាសមិនមែនសេដ្ឋកិច្ចមួយចំនួនដូចជា ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ បច្ចេកវិទ្យា ព័ត៌មានវិទ្យានិងទូរគមនាគមន៍ ការអភិវឌ្ឍន៍ធនធានមនុស្ស និងសន្តិសុខ ។ តំបន់ពាណិជ្ជកម្មសេរីនេះ ក៏នឹងពង្រឹងទំនាក់ទំនងដ៏ជិតស្និទ្ធជាងមុន រវាងកម្ពុជា និងចិន ក្នុងកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ។

### *៣.២.២. បញ្ហាប្រឈម*

តំបន់ពាណិជ្ជកម្មសេរីនេះ នឹងបង្កអោយមានបញ្ហាប្រឈមចំបងៗមួយចំនួនដល់កម្ពុជា ដូចជាការអនុវត្តន៍កំណែទំរង់គន្លឹះៗ ការប្រើប្រាស់គំរោងសេរីភាវូបនីយកម្មអោយប្រសើរបំផុត ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសក្នុងស្រុក និងការរិះរកវិធានការដើម្បីបញ្ចៀសឥទ្ធិពលអវិជ្ជមាន ។ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗជាងគេ គឺការបង្កើនសមត្ថភាពវិស័យឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងតំបន់ ។ សហគ្រាសកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលមានសមត្ថភាពផលិតកម្ម និងទីផ្សារ មានកំណត់ ។ សមត្ថភាពមានកំណត់ និងបរិយាកាសអាជីវកម្មមិនអំណោយផលនេះ បានរារាំងសហគ្រាសកម្ពុជា មិនឱ្យទទួលបានអត្ថប្រយោជន៍ច្រើនពីសិទ្ធិចូលទីផ្សារ ។ បទពិសោធន៍ក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន បង្ហាញថា កម្ពុជាបានប្រើប្រាស់តិចតួចបំផុតនូវ គំរោងសេរីភាវូបនីយកម្មដែលផ្តល់ដោយប្រទេសអាស៊ានដទៃទៀត ។ ទោះបីជាអត្រាពន្ធគយលើទំនិញភាគច្រើនត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ក្រោមគំរោងអនុគ្រោះពន្ធរួមគ្នី (CEPT) ក៏ការនាំចេញរបស់កម្ពុជាទៅទីផ្សារអាស៊ានពុំបានកើនឡើងច្រើនឡើយ ។ គេជឿថា រឿងនេះសំខាន់មកពី ផលិតករកម្ពុជាជួបឧបសគ្គខាងផ្នែកផ្គត់ផ្គង់ធំៗជាច្រើនដូចជា បរិយាកាសអាជីវកម្មនិងវិនិយោគទុនមិនអំណោយផល ក្របខ័ណ្ឌច្បាប់មិនគ្រប់គ្រាន់ កង្វះខាតអភិបាលកិច្ចល្អនិងស្ថាប័នប្រកបដោយប្រសិទ្ធភាព ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនគ្រប់គ្រាន់ កង្វះខាតប្រភពហិរញ្ញវត្ថុ និងសេវាកម្មគាំទ្រអាជីវកម្ម ហើយនិងកង្វះខាតជំនាញបច្ចេកទេស និងគ្រប់គ្រង ។ ដោយសារកង្វះសមត្ថភាពនៃ

---

៣ ក្រុមអ្នកនិពន្ធ អង្កេតអំពីកត្តាកំនត់ឧត្តមភាពប្រៀបធៀបរបស់ប្រទេសសមាជិកអាស៊ានមួយចំនួន ដោយផ្អែកលើភស្តុតាងសំអាងលើការពិនិត្យឃើញជាក់ស្តែងតាមពីការសិក្សាប្រទេសផ្សេងៗ ដោយលោក Wood Adrian (1994): *Skills, Land and Trade: A simple Analytical Framework.* IDS working paper 1 (Brighton : Institute of Development Studies)

ស្ថាប័នសាធារណៈ និងដោយសារអាទិភាពអភិវឌ្ឍន៍ដទៃទៀតរបស់រដ្ឋាភិបាល ការដោះស្រាយកំហិតខាងការផ្គត់ផ្គង់ និងការបង្កើនការនាំចេញរបស់កម្ពុជា នឹងមានភាពលំបាកបំផុត ។

បញ្ហាប្រឈមចំបងមួយទៀត គឺការបង្កើតយន្តការដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ។ នៅពេលរនាំងពាណិជ្ជកម្មត្រូវបានរំលាយ ឧស្សាហកម្មខ្លះនឹងរីកលូតលាស់ ឯឧស្សាហកម្មខ្លះទៀតនឹងធ្លាក់ចុះដោយសារការប្រកួតប្រជែង ហើយនឹងមានការបែងចែកផលចំណេញ និងការខាតបង់មិនស្មើគ្នាក្នុងចំណោមវិស័យផ្សេងៗ ។ នៅពេលមានការលុបបំបាត់តារាងពន្ធគយ ទីផ្សារកម្ពុជានឹងពេញដោយទំនិញនាំចូលថោកៗពីចិន ដែលនាំឱ្យមានការប្រកួតប្រជែងខ្លាំងជាងមុនជាមួយផលិតផលក្នុងស្រុក ។ ក្រុមហ៊ុនក្នុងស្រុកដែលមិនអាចប្រកួត ប្រជែងបាននឹងត្រូវបិទទ្វារ ហើយវាអាចបង្កការបាត់បង់ការងាររយៈពេលខ្លី ការធ្លាក់ចុះចំណូល និងការឈានទៅរកភាពក្រីក្រ ។ ទោះបីជាកម្ពុជាត្រូវបានគេផ្តល់ភាពបត់បែន និងពេលវេលាច្រើនក្តី ក៏ការលំបាកនឹងកើតមានឡើង ដោយសារកង្វះធនធានហិរញ្ញវត្ថុ និងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តកម្មវិធីកំណែទំរង់ ។

ការព្រួយបារម្ភមួយផ្សេងទៀតសំរាប់កម្ពុជា គឺធ្វើយ៉ាងណាធ្វើចំរុះកម្មប្រភពចំណូល ដើម្បីកាត់បន្ថយការពឹងផ្អែកលើពន្ធពាណិជ្ជកម្ម ដើម្បីផ្តល់មធ្យោបាយហិរញ្ញវត្ថុសំរាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ។ ការកាត់បន្ថយតារាងពន្ធគយអាចបង្កអោយចំណូលធ្លាក់ចុះ ដូច្នេះអាចធ្វើអោយមានបញ្ហាលំបាកដល់គោលនយោបាយសារពើពន្ធ ។ សមត្ថភាពសារពើពន្ធខ្សោយអាចបង្អាក់ការចំណាយចាំបាច់ក្នុងវិស័យផ្សេងទៀត ដូចជា អប់រំ សុខាភិបាល និង កសិកម្ម ។ បញ្ហានេះអាចបង្អាក់ដំណើរការអភិវឌ្ឍន៍ ។

## ៣.៣. ឥទ្ធិពលជាសក្តានុពលនៃកម្មវិធីប្រមូលផលដើមដៃលើវិស័យកសិកម្មកម្ពុជា

កសិកម្មនៅកម្ពុជាមានលក្ខណៈជាកសិកម្មដែលប្រើបច្ចេកវិទ្យាទាប ពឹងផ្អែកខ្លាំងលើអាកាសធាតុ មានផលិតភាពទាប និងមានការរីកចំរើនរអាក់រអួល ។ វិស័យនេះតំណាងអោយ ៣១% នៃផលិតផលក្នុងស្រុកសរុប ហើយប្រើប្រាស់អស់ប្រហែល ៧០% នៃកំលាំងពលកម្មសរុប (CDRI, 2005) ។ កង្វះខាតផលិតកម្មសំរាប់ការនាំចេញ និងវិនិយោគឯកជននៅតែធ្វើអោយវិស័យនេះមិនរីកចំរើន ដូច្នេះឧត្តមភាពប្រៀបធៀបសក្តានុពល នឹងមិនសំរេច បានទាំងស្រុងទេ ។ ជាមួយនឹងកម្មវិធីប្រមូលផលដើមដៃ គេរំពឹងថា ការនាំចេញផលិតផលកសិកម្មកម្ពុជានឹងកើនឡើងជាលំដាប់ ដែលអាចបង្កើនធនធាន និងវិនិយោគឯកជនបានច្រើនជាងមុនដើម្បីអភិវឌ្ឍន៍វិស័យនេះ ។

រចនាសម្ព័ន្ធពាណិជ្ជកម្មរវាងចិន និងថៃ ព្រមទាំងរវាង ចិន និងវៀតណាម ដូចដែលមានចុះក្នុងតារាង A.3 ក្នុងឧបសម្ព័ន្ធស្ថិតិបង្ហាញថា ទីផ្សារចិនមានតំរូវការយ៉ាងច្រើនលើសលុបនូវផលិតផលក្នុងជំពូកទី ៧ (បន្លែ អាចហូបបាន ឫស និងមើម) ជំពូកទី ៨ (ផ្លែឈើ និងគ្រាប់ផ្លែឈើអាចហូបបាន) និងជំពូកទី ៣ (ត្រី សត្វវង្គសត្វ និងសិប្បិសត្វ) ។ ក្នុងឆ្នាំ២០០៥ ចិនបាននាំចូលដំឡូងឈើចំនួន ៣៤១លានដុល្លារ ពីថៃ និង៥០លានដុល្លារ ពីវៀតណាម ។ ចិនក៏នាំចូលផ្លែឈើ និងគ្រាប់ឈើអាចហូបបានចំនួន ១៨០លានដុល្លារ ត្រី និងសត្វវង្គសត្វចំនួន ៥៧លានដុល្លារ ពីថៃ ។ ផ្លែឈើស្រស់ដូចជា ម្នាស់ ស្វាយ មង្ឃុត ធូរេន មៀន និងចេក ព្រមទាំងផលិតផលដទៃទៀត ដូចជា ដំឡូងឈើ ត្រី បង្គារ គឺជាផលិតផលនាំចូលដ៏សំខាន់របស់ចិន ។ ក្នុងចំណោមផលិតផលទាំងនេះ មានផលិតផលខ្លះដូចជា ត្រី បង្គារ គឺជាផលិតផលនាំចេញបច្ចុប្បន្នរបស់កម្ពុជាទៅកាន់ចិន ឯខ្លះទៀតគឺជាផលិតផលនាំចេញសក្តានុពលរបស់កម្ពុជា ។ ដូច្នេះសិទ្ធិចូលទីផ្សារចិនតាមរយៈកម្មវិធីប្រមូលផលដើមដៃ ព្រមទាំងតំរូវការដ៏សន្ធឹកសន្ធាប់ពីទីផ្សារចិន អាចជំរុញអោយមានការពង្រីកផលិតកម្មនៃផលិតផលកសិកម្មទាំងនោះ ។ ដំឡូងឈើកម្ពុជាមានសក្តានុពលយ៉ាងខ្លាំងក្នុងការនាំចេញទៅកាន់ចិន ដោយសារសមត្ថភាពប្រកួតប្រជែងនៃផលិតផលដំឡូងឈើនេះ អាចប្រៀបធៀបបានជាមួយដំឡូងឈើរបស់ថៃ និងវៀតណាម ។ ម្យ៉ាងទៀត កម្មវិធីនេះអាចផ្តល់សក្តានុពលខ្ពស់ដល់កម្ពុជា ក្នុងការ

នាំចេញផលិតផលផ្លែឈើស្រស់មួយចំនួន ដូចជា ធូរេន ម្នាស់ មៀន និងចេក ។ ទោះបីជា កម្ពុជាពុំរាប់បញ្ចូលផលិតផលទាំងនេះក្នុងតារាងទំនិញសំរាប់ធ្វើសេរីភាវូបនីយកម្មក្តី ក៏កម្ពុជាអាចទទួលបានការអនុគ្រោះពន្ធគយខ្លះ ពីចិនតាមរយៈប្រព្រឹត្តិកម្មអនុគ្រោះពិសេសលើមុខទំនិញចំនួន ៣៨០មុខ ដែលក្នុងនោះមាន ១៥៥មុខ ស្ថិតក្នុងកម្មវិធីប្រមូលផលដើមដៃ ។ ការដាំដុះផ្លែឈើស្រស់នៅកម្ពុជា មានលក្ខណៈធម្មជាតិ ហើយមានរសជាតិប្លែកពិសេសពីផ្លែឈើរបស់ប្រទេសវៀតណាម និងថៃ ។ បញ្ហានេះធ្វើអោយផ្លែឈើស្រស់កម្ពុជា អាចជៀសវាងពីការប្រកួតប្រជែងដោយផ្ទាល់ជាមួយប្រទេសដទៃទៀត ដូច្នេះអាចធ្វើកម្ពុជាងាយស្រួលវាយលុកចូលទីផ្សារចិនមួយផ្នែក ។

ឱកាសមួយទៀតដែលផ្សារភ្ជាប់ជាមួយនឹងកម្មវិធីប្រមូលផលដើមដៃ គឺការនាំចេញគ្រាប់ស្វាយចន្ទី ។ ផលិតកម្មស្វាយចន្ទីរបស់កម្ពុជាកំពុងរីកដុះដាល ជាពិសេសសំរាប់ទីផ្សារបរទេស ។ ដោយសារចិននាំចូលគ្រាប់ស្វាយចន្ទីយ៉ាងច្រើនពីថៃ និងដោយសារពន្ធគយអនុគ្រោះក្រោមកម្មវិធីប្រមូលផលដើមដៃ គេរំពឹងថា គ្រាប់ស្វាយចន្ទីកម្ពុជាអាចនាំចេញទៅប្រទេសចិន ហើយនៅពេលនោះផលិតកម្មស្វាយចន្ទីនឹងរីកលូតលាស់ ។

សំរាប់ការនាំចេញ ត្រី និងបង្គា វាមានការលំបាកសំរាប់កម្ពុជា ពីព្រោះមានគូប្រជែងខ្លាំងជាងមកពីថៃ និងវៀតណាម ដែលត្រូវបានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះស្រដៀងគ្នាពីចិន ។ ប្រទេសទាំងនេះសុទ្ធតែជាប្រទេស នាំចេញយ៉ាងធំនូវផលិតផលបែបនោះ ហើយអាចផលិតបានប្រសិទ្ធភាពខ្ពស់ជាងកម្ពុជា ។ ប្រសិនបើកម្ពុជាមិនអាចរកបានទីផ្សារដោយឡែកណាមួយទេនោះ ការនាំចេញផលិតផលទាំងនេះអាចប្រឈមនឹងការគំរាមកំហែងពីការប្រកួតប្រជែងផ្ទាល់ ។ ស្ថិតិក្នុងតារាងទី ៣ បង្ហាញពីការធ្លាក់ចុះជាលំដាប់នៃការនាំចេញផលិតផលទាំងនេះ ហើយនិន្នាការសំរាប់ប៉ុន្មានឆ្នាំខាងមុខ នឹងពុំមានការផ្លាស់ប្តូរជាដុំកំភួនឡើយ លើកលែងតែផលិតផលទាំងនេះអាចបំពេញតាមតំរូវការដោយឡែកណាមួយនៅក្នុងទីផ្សារប្រទេសចិន ។

ឥទ្ធិពលដែលកម្មវិធីនេះអាចមានលើផលិតករក្នុងស្រុក ហាក់ដូចជាតិចតួចណាស់ ។ ស្ថិតិពាណិជ្ជកម្មលើផលិតផលក្នុងកម្មវិធីរវាងកម្ពុជា និងចិន ក្នុងតារាងទី ៣ បង្ហាញពីការបំពេញគ្នាទៅវិញទៅមកយ៉ាងច្រើននៃការនាំចេញរវាងប្រទេសទាំងពីរ ដូច្នេះឥទ្ធិពលអវិជ្ជមានដែលអាចមានមិនធំណាស់ណាទេ ។ ម្យ៉ាងទៀត ផលិតផលមួយចំនួនដូចជា ប៉េងប៉ោះ ខ្ទឹមបារាំង ខ្ទឹមស ស្ពៃក្តោប ការ៉ុត ដែលកសិករតូចៗផលិត សំរាប់ទីផ្សារក្នុងស្រុក សុទ្ធតែត្រូវដកចេញពីការបញ្ចុះអត្រាពន្ធគយ ។ ប៉ុន្តែកសិករកម្ពុជាបានទទួលការប៉ះពាល់ រួចហើយពីការហូរចូលផលិតផលមកពីប្រទេសវៀតណាម ហើយដែលផលិតផលមកពីចិនមិនអាចប្រកួតប្រជែងបាន ។ បើយើងវិនិច្ឆ័យដោយផ្អែកលើរចនាសម្ព័ន្ធពាណិជ្ជកម្មបច្ចុប្បន្នរវាងកម្ពុជា និងចិន វាហាក់ដូចជា ពុំមានផលិតផលណាផ្សេងទៀត ដែលអាចមានការប៉ះពាល់អវិជ្ជមានខ្លាំងក្លាដោយការនាំចូលពីចិន តាមរយៈកម្មវិធីប្រមូលផលដើមដៃទេ ។

## ៣.៤. ផលប៉ះពាល់លើភាពក្រីក្រ

កម្ពុជាស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងតំបន់ ដែលមានភាពក្រីក្ររាលដាលយ៉ាងខ្លាំង ដោយសារការបំផ្លិចបំផ្លាញ និងសង្គ្រាមអស់រយៈពេលជាច្រើនទសវត្សរ៍ ។ ប្រជាជនកម្ពុជាប្រហែល ៣៦% រស់ក្រោមបន្ទាត់ភាពក្រីក្រ ហើយភាគច្រើននៃអ្នកក្រីក្រទាំងនេះជាមេគ្រួសារដែលប្រកបរបរកសិកម្ម (Ministry of Planning, 1997) ។

កម្មវិធីប្រមូលផលដើមដៃ ផ្តល់ឱកាសជាច្រើនសំរាប់ការនាំចេញផលិតផលកសិកម្មមួយចំនួនទៅប្រទេសចិន ។ ក៏វិតអត្ថប្រយោជន៍សំរាប់អ្នកក្រីក្រ ពឹងផ្អែកលើថា តើអ្នកក្រីក្រទាំងនេះ ជាពិសេសអ្នករស់នៅជនបទ អាចចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មបានក៏វិតណា តាមរយៈការផ្គត់ផ្គង់ទំនិញនាំចេញ ឬក៏ធ្វើការក្នុងវិស័យមាន ភាពប្រកួតប្រជែងខ្ពស់ និងការងារពាក់ព័ន្ធផ្សេងទៀត ។ ផលប្រយោជន៍សុទ្ធសំរាប់អ្នកក្រីក្រ ក៏ពឹងផ្អែកលើថា តើគោលនយោបាយថ្នាក់តំបន់ និងក្នុងស្រុក គាំពារ

អ្នកក្រីក្រករិតណា ។ កម្មវិធីប្រមូលផលដើមដៃ នឹងផ្តល់ ប្រយោជន៍ដល់អ្នកក្រីក្រ ប្រសិនបើគោលនយោបាយត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍប្រព័ន្ធកសិកម្ម និងទីផ្សារ ផលិតផលកសិកម្ម ដែលសំរួលដល់កសិករធុនតូចអោយផ្គត់ផ្គង់ផលិតផលកសិកម្មប្រកបដោយប្រសិទ្ធភាពថ្លៃដើមខ្ពស់ ។ កសិករ ក៏អាចនឹងទទួលបានផលប្រយោជន៍ពីគោលនយោបាយដែលជួយអភិវឌ្ឍសហគ្រាសក្នុងស្រុក ជាពិសេសសហគ្រាសធុនតូច និងមធ្យម ដើម្បីអោយមានសមត្ថភាពគ្រប់គ្រាន់អាចប្រកួតប្រជែងក្នុងទីផ្សារតំបន់ និងអន្តរជាតិ ។

លើសពីនេះទៀត វាមានភាពចាំបាច់ណាស់ដែលគេត្រូវមានវិធានការកែសំរួល ដើម្បីបញ្ចៀសឥទ្ធិពលអវិជ្ជមានដែលអាចផុសចេញពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ អន្តរាគមន៍គោលនយោបាយ និងការគាំទ្ររបស់រដ្ឋាភិបាលដែលសំដៅផ្តល់សំណាញ់សុវត្ថិភាព និងឱកាសការងារផ្សេងៗ សំរាប់កសិករធុនតូច និងអ្នកក្រីក្រមានភាពចាំបាច់ណាស់ដែរ ។

ជារួម យ៉ាងហោចណាស់ក្នុងរយៈពេលខ្លីនិងមធ្យម វិស័យកសិកម្មកម្ពុជា នឹងមិនទំនងជាមានផលប៉ះពាល់អវិជ្ជមានជាដុំកំភួនពីកម្មវិធីប្រមូលផលដើមដៃទេ ។ ផ្ទុយទៅវិញ គេរំពឹងថាកម្មវិធីនេះ នឹងផ្តល់ឱកាសនាំចេញ ក្រោមអត្រាពន្ធគយអនុគ្រោះដល់ផលិតផលកសិកម្មកម្ពុជា ជាពិសេសសំរាប់ផ្លែឈើស្រស់ ។ ការពង្រីកផលិតកម្ម និងការនាំចេញផលិតផលកសិកម្មនឹងជួយបានច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ បើសិនមានការបង្កើតនិងរៀបចំ គោលនយោបាយជាតិដើម្បីគាំទ្រដល់ការចូលរួមរបស់អ្នកក្រីក្រក្នុងសកម្មភាពពាក់ព័ន្ធនឹងពាណិជ្ជកម្មកសិកម្ម ។

# ជំពូកទី ៤.
# កិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជា

ជំពូកនេះសង្ខេបត្រួសៗពីកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក ថ្នាក់តំបន់ និងទ្វេភាគីដែលកម្ពុជាបានចុះហត្ថលេខា និងមានការរៀបរាប់ពីការប្តេជ្ញារបស់កម្ពុជាក្រោយចូលជាសមាជិកអង្គការ WTO ទំរង់នៃការកាត់បន្ថយ និងលុបបំបាត់តារាងពន្ធគយក្រោមគំរោង CEPT/AFTA កម្មវិធីគាំទ្រមហាអនុតំបន់ទន្លេមេគង្គ និងពីចារិកលក្ខណៈនៃពាណិជ្ជកម្មទ្វេភាគី ហើយបន្ទាប់មក មានការពិភាក្សាលើផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម ទាំងនេះលើវិស័យកសិកម្មកម្ពុជា ។ ក្រោយពីអន្តរកាលឆ្ពោះទៅសេដ្ឋកិច្ចទីផ្សារជាងមួយទសវត្សរ៍ កម្ពុជា បានសំរេចនូវសមិទ្ធិផលយ៉ាងច្រើនក្នុងការធ្វើសមាហរណកម្មចូលទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ កម្ពុជា បានចូលក្នុងអង្គការ WTO ដោយមានការប្តេជ្ញាចិត្តជាច្រើន ដើម្បីគោរពតាមគោលការណ៍ និងវិធានពាណិជ្ជកម្មពហុភាគី ។ នៅថ្នាក់តំបន់ កម្ពុជាបានក្លាយជាសមាជិកអាស៊ាន និង AFTA ក្នុងឆ្នាំ១៩៩៩ និងជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនៅឆ្នាំ២០០២ ។ កម្ពុជា ក៏ជាសមាជិកមហាអនុតំបន់ទន្លេមេគង្គ ដើម្បីជំរុញទំនាក់ទំនងសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការឱ្យស្និទ្ធស្នាលជាងមុន ។ កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសមួយចំនួនមានជាអាទិ៍ ចិន សហភាពអឺរ៉ុប ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សូវៀត ថៃ សហរដ្ឋអាមេរិក និងវៀតណាម ។ កិច្ចព្រមព្រៀងទាំងនេះ មានគោលបំណងចំបងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ តាមរយៈការស្តារទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មឡើងវិញ និងផ្តល់នូវលក្ខខណ្ឌ MFN ជាជាងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មដោយកាត់បន្ថយ និងលុបបំបាត់អត្រាពន្ធគយ ។ ការវិវត្តន៍ទាំងនេះ នាំអោយនយោបាយពាណិជ្ជកម្មកម្ពុជា មានការបើកចំហនិងសេរីជាងមុន ស្របជាមួយនឹងការរីកសាយភាយនូវការរៀបចំបង្កើតជាតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម ។

## ៤.១. ថ្នាក់សាកលលោក

កម្ពុជាបានក្លាយជាសមាជិកទី១៤៨ នៃអង្គការ WTO នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ ។ កម្ពុជា នឹងអាចទទួលសិទ្ធិ និងកាតព្វកិច្ចពេញលេញក្រោមកិច្ចព្រមព្រៀងរបស់ WTO ដូចជា កាតព្វកិច្ចមិនធ្វើការរើសអើង និងសិទ្ធិប្រើប្រាស់នីតិវិធីដោះស្រាយទំនាស់របស់អង្គការនេះ ។ ក្នុងពេលជាមួយគ្នា កម្ពុជាត្រូវគោរពតាមវិធាន និងគោលការណ៍របស់ WTO ។ ជាលទ្ធផល កម្ពុជាបានប្តេជ្ញាអនុម័តច្បាប់ជាច្រើនដើម្បី ពង្រឹងប្រព័ន្ធតុលាការ ចំពោះសកម្មភាពពាណិជ្ជកម្ម ពង្រឹងការគោរពសិទ្ធិកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងពាណិជ្ជកម្ម សំរបសំរួលមុខងារ ពាណិជ្ជកម្មក្រៅប្រទេសឱ្យមានភាពរលូន និងជំរុញអន្តរកម្មហិរញ្ញវត្ថុ ។ ក្រៅពីនេះទៀត កម្ពុជាបានធ្វើការប្តេជ្ញា ជាច្រើនផ្សេងទៀតដើម្បីធ្វើអោយគោលនយោបាយពាណិជ្ជកម្ម និងការអនុវត្តន៍ជាក់ស្តែង មានលក្ខណៈយុត្តិធម៌ និងមិនរើសអើង មានតម្លាភាព និងអាចប្រមាណទុកមុន ។ ការប្តេជ្ញាដូចមានចែងក្នុងរបាយការណ៍ក្រុមការងារស្តីពី ការបញ្ចូលកម្ពុជាក្នុងអង្គការ WTO (WT/ACC/KHM/21) គឺជាប់ទាក់ទងនឹងកម្មសិទ្ធិរដ្ឋ និងឯកជនភាវូបនីយកម្ម គោលនយោបាយកំណត់ថ្លៃ អត្រាពន្ធគយ ការលើកលែងពន្ធគយ និងកូតា ការរឹតត្បិតបរិមាណនាំចូល ការរឹតត្បិតការនាំចេញ ឧបត្ថម្ភធននាំចេញ វិធានការប្រឆាំងការលក់បង្ខូចថ្លៃ របបគាំពារនិងពន្ធអាករទប់ទល់ ការកំណត់តំលៃ

គិតពន្ធគយ អធិការកិច្ចមុនពេលផ្ទុក ច្បាប់ប្រភពដើម គោលនយោបាយឧស្សាហកម្ម គោលនយោបាយកសិកម្ម ស្តង់ដារ និង លិខិតបញ្ជាក់ និងរបបវាយនភណ្ឌ (សូមមើលឧបសម្ព័ន្ធ) ។

សមាជិកភាពរបស់កម្ពុជាក្នុង WTO ជាឧបករណ៍សំរាប់ធ្វើកំណែទំរង់ក្នុងស្រុកដែលមានបំណងចំបង ផ្តល់ក្របខ័ណ្ឌច្បាប់ មានតម្លាភាព និងបរិយាកាសអាជីវកម្មដែលយុត្តិធម៌និងអាចប្រមាណទុក ។ បទប្បញ្ញត្តិ និងក្របខ័ណ្ឌជាមូលដ្ឋានទាំងនេះ រួម ជាមួយនឹងការអនុវត្តន៍សកម្មភាពពាណិជ្ជកម្មដោយមានតម្លាភាព និងយុត្តិធម៌ អាចសំរួលការអនុវត្តន៍គំរោងសេរីភាវូបនីយកម្ម ពាណិជ្ជកម្មទ្វេភាគីថ្នាក់តំបន់ និងពិភពលោក ។ ផលចំណេញមួយ ក្នុងចំណោមផលចំណេញចំបង១សំរាប់កម្ពុជា ក្រោយបាន ចូលជាសមាជិក WTO គឺការនាំចេញសំលៀកបំពាក់ មិនស្ថិតក្រោមរបបកូតាទៀតឡើយ បន្ទាប់ពីកិច្ចព្រមព្រៀងវាយនភណ្ឌ និងសំលៀកបំពាក់ ត្រូវបញ្ចប់ក្នុងខែមករា ឆ្នាំ២០០៥[៤] ។ អត្ថប្រយោជន៍នេះធ្វើអោយកម្ពុជាមានប្រៀបជាងកាលពីមិនទាន់ ចូលសមាជិក WTO ហើយវាអាចជួយជំរុញសមត្ថភាពប្រកួតប្រជែងនៃវិស័យកាត់ដេរ ដែលជាប្រភពដ៏សំខាន់នៃការងារ ការរក ចំណូល រូបិយវត្ថុបរទេស និងកំនើនសេដ្ឋកិច្ច ។ សេចក្តីសង្ឃឹមរយៈពេលវែងមួយទៀតសំរាប់កម្ពុជា គឺឱកាសអភិវឌ្ឍន៍វិស័យ កសិកម្មតាមរយៈលទ្ធភាពទទួលបានទីផ្សារសកលប្រសើរជាងមុន ។ ក្នុងរយៈពេលខ្លី និងមធ្យម កសិកម្មកម្ពុជាមិនទំនងជា អាចទាញប្រយោជន៍បានច្រើនពីប្រព័ន្ធពាណិជ្ជកម្មសកលទេ ដោយសារហេតុផលសំខាន់ពីរ ។ ទីមួយ មកពីដំណើរការចរចារបស់ WTO លើសេរីភាវូបនីយកម្មកសិកម្ម មានភាពយឺតយ៉ាវ ដូច្នេះ ឧបសគ្គនៅតែមានច្រើនណាស់ចំពោះពាណិជ្ជកម្មកសិកម្ម ។ ទីពីរ មកពីផលិតកម្ម និងទីផ្សារកសិកម្មកម្ពុជាពុំទាន់អភិវឌ្ឍន៍បានល្អ ដោយសារមានឧបសគ្គជាច្រើន ដូចជា ហេដ្ឋារចនាសម្ព័ន្ធ មិនល្អប្រសើរ កង្វះក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ ពុំមានប្រព័ន្ធទីផ្សារមានប្រសិទ្ធភាព កង្វះបច្ចេកវិទ្យាសមស្រប សេវាកម្មបច្ចេកទេសមិនគ្រប់គ្រាន់ និងរចនាសម្ព័ន្ធហិរញ្ញវត្ថុជនបទមិនគ្រប់គ្រាន់ ។ បញ្ហានេះធ្វើអោយកសិកម្ម កម្ពុជាមាន សមត្ថភាពប្រកួតប្រជែងទាប ហើយមិនអាចផ្គត់ផ្គង់ដល់ទីផ្សារសកលបាន ។

## ៤.២. ថ្នាក់តំបន់

### *៤.២.១. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA)*

កម្ពុជាចូលអាស៊ានក្នុងឆ្នាំ១៩៩៩ ហើយជាស្វ័យប្រវត្តិក៏ក្លាយជាសមាជិក AFTA ។ AFTA ត្រូវបានបង្កើតឡើងជាផ្លូវការក្នុង ឆ្នាំ១៩៩២ ដោយមានគោលបំណងចំបងបង្កើនល្បឿនសេរីភាវូបនីយកម្ម វិនិយោគទុនក្នុងតំបន់ ព្រមទាំងសំរេចអោយបាននូវ តំបន់ពាណិជ្ជកម្មសេរីនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៣[៥] ។ គំរោងអនុគ្រោះពន្ធគយរួម (CEPT) គឺជាឧបករណ៍ដ៏សំខាន់ សំរាប់ការបញ្ចុះអត្រាពន្ធគយលើរាល់ផលិតផល ឧស្សាហកម្ម ដូចជា ទំនិញមូលធន ផលិតផលកសិកម្មកែច្នៃ ផលិតផល កសិកម្ម[៦] និងផលិតផលមិនមែនកសិកម្ម ។ CEPT បែងចែកផលិតផលធ្វើពាណិជ្ជកម្មជា ៤ ប្រភេទសំរាប់ការកាត់បន្ថយ អត្រាពន្ធគយ គឺបញ្ជីទំនិញរាប់បញ្ចូល (IL) បញ្ជីទំនិញលើកលែងបណ្តោះអាសន្ន (TEL) បញ្ជីទំនិញរសើប (SL) និងបញ្ជីទំនិញ

---

[៤] កិច្ចព្រមព្រៀងនេះ ជំនួសឱ្យកិច្ចព្រមព្រៀងសរសៃអំបោះ (MFA) ក្នុងឆ្នាំ១៩៩៥ ក្នុងលក្ខណៈជាឧបករណ៍អន្តរកាលដើម្បីបញ្ចូលវិស័យ កាត់ដេរក្នុងច្បាប់ GATT ក្នុងរយៈពេល ១០ឆ្នាំ ។ ក្នុងខែមករា ២០០៥ វិស័យវាយនភណ្ឌ និងសំលៀកបំពាក់សាកល លែងស្ថិតនៅ ក្រោមកំរិតកូតាទៀតហើយ លើកលែងតែវាមានលក្ខណៈគ្រប់គ្រាន់ត្រូវស្ថិតក្រោមវិធានការការពារសុវត្ថិភាព ដូចបានចែងនៅក្នុង កិច្ចព្រមព្រៀង ។

[៥] ពេលវេលាដើមសំរាប់សេរីភាវូបនីយកម្មនេះ មានរយៈពេល ១៥ឆ្នាំ គិតចាប់ពីឆ្នាំ១៩៩៣ ។ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ច អាស៊ាន លើកទី ២៦ បានកាត់បន្ថយពេលវេលានេះមកត្រឹម ១០ឆ្នាំវិញ ។

[៦] ក្នុងខែតុលា ឆ្នាំ១៩៩៤ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានសំរេចបញ្ចូលផលិតផលកសិកម្មក្នុង CEPT ។

លើកលែងទូទៅ (GEL) (Kanokpan Lao-Araya, 2002) ។ IL មានផលិតផលដែលត្រូវកាត់បន្ថយអត្រាពន្ធគយភ្លាមឱ្យដល់កំរិតពី 0-៥% ត្រឹមឆ្នាំ២០០៣ ។ TEL សំដៅលើទំនិញដែលនឹងត្រូវកាត់បន្ថយពន្ធដល់ 0-៥% ប៉ុន្តែត្រូវបានការពារបណ្តោះអាសន្នសិន ។ SL គឺជាផលិតផលកសិកម្មមិនកែច្នៃដែលនឹងត្រូវដាក់បញ្ចូលក្នុង IL រវាងឆ្នាំ២០០១ និង ២០០៣ ហើយនឹងត្រូវកាត់បន្ថយអត្រាពន្ធគយដល់ 0-៥% ត្រឹមឆ្នាំ២០១០ ។ GEL សំដៅលើផលិតផលដែល ប្រទេសនីមួយៗយល់ថាចាំបាច់សំរាប់ការការពារសន្តិសុខជាតិ សីលធម៌សាធារណៈ ជីវិត និងសុខភាពមនុស្ស សត្វ រុក្ខជាតិ និងវត្ថុមានតំលៃសិល្បៈ ប្រវត្តិសាស្ត្រ ឬតំលៃស្ថាបត្យកម្ម ។

ការនាំចេញផលិតផលកសិកម្មរបស់កម្ពុជាទៅទីផ្សារអាស៊ាន មានចំនួនតិចជាងការនាំចូល ។ ការលុបបំបាត់រនាំងពាណិជ្ជកម្មក្រោម CEPT/AFTA នាំឱ្យមានកំនើនយ៉ាងសន្ធឹកសន្ធាប់នូវការនាំចូលផលិតផលកសិកម្ម ពីថៃ និងវៀតណាម ។ ពីបទពិសោធន៍នេះហាក់ដូចជាបញ្ជាក់ថា កសិកម្មកម្ពុជាពុំអាចទាញ ប្រយោជន៍បានច្រើនបំផុតពី AFTA ដោយសារមូលហេតុចំបងពីរយ៉ាង ។ ទីមួយ ការនាំចេញផលិតផលកសិកម្ម ក្នុងចំណោមប្រទេសកម្ពុជា វៀតណាម ថៃ ឥណ្ឌូនេស៊ី និងឡាវ មានភាពស្រដៀងគ្នាច្រើន ដែលធ្វើអោយមានការ ប្រកួតប្រជែងខ្លាំង ។ ដូច្នេះប្រទេសដែលអាចផលិតដោយមានភាពប្រកួតប្រជែងខ្ពស់ដូចជា ថៃ និងវៀតណាម បានគ្របដណ្តប់លើទីផ្សារក្នុងតំបន់ ។ ទីពីរ វិស័យកសិកម្មកម្ពុជានៅតែមានភាពអន់ខ្សោយ ហើយការអភិវឌ្ឍន៍វិស័យនេះត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើន ។ បញ្ហានេះនៅតែធ្វើអោយវិស័យកសិកម្មកម្ពុជា មានសមត្ថភាពប្រកួតប្រជែងទាបជាងប្រទេសជិតខាង ។

### *៤.២.២. មហាអនុតំបន់ទន្លេមេគង្គ*

កម្ពុជាជាសមាជិក GMS ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩២ ក្រោមជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងចំណោមប្រទេស ៦ តាមបណ្តោយទន្លេមេគង្គគឺមាន កម្ពុជា ឡាវ ភូមា ថៃ វៀតណាម និងខេត្តយូណាននៃប្រទេសចិន ។ GMS មានគោលដៅធំសំខាន់ដើម្បីជំរុញការអភិវឌ្ឍន៍ទីផ្សារ GMS និងចលនាទំនិញនិងធនធានមនុស្សឆ្លងកាត់ព្រំដែនរួម ។ គោលដៅជាក់លាក់សំខាន់ៗមាន (១) សំរួលវិនិយោគទុន និងពាណិជ្ជកម្ម ក្នុងអនុតំបន់ (២) សំរួលឱកាសអភិវឌ្ឍន៍អនុតំបន់ ជាពិសេសវិស័យថាមពល និងទេសចរណ៍, (៣) សំរួលដំណោះស្រាយបញ្ហាឆ្លងកាត់ព្រំដែនដូចជា ជំងឺឆ្លង និងការបំផ្លាញបរិស្ថាន និង (៤) បំពេញតំរូវការធនធានរួម ឬតំរូវការផ្សេងទៀត ។ ដើម្បីបង្កើនចំណងមិត្តភាព និងទំនាក់ទំនងក្នុងតំបន់ GMS បានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ប្រព័ន្ធគមនាគមន៍ និងរបៀងសេដ្ឋកិច្ចភ្ជាប់ពីប្រទេសមួយទៅមួយ ។ វិស័យអាទិភាពដទៃទៀត រួមមាន ថាមពល ទូរគមនាគមន៍ បរិស្ថាន ការអភិវឌ្ឍន៍ធនធានមនុស្ស ទេសចរណ៍ ពាណិជ្ជកម្ម វិនិយោគទុនវិស័យឯកជន និងកសិកម្ម ។

មហាអនុតំបន់ទន្លេមេគង្គ (GMS) មានការដឹកនាំដោយសំនុំគោលការណ៍ទូទៅមួយចំនួន គឺខុសពីអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដែលជាការប្រមូលផ្តុំកិច្ចព្រមព្រៀងតាមផ្លូវការច្បាប់ និងបែបស្ថាប័ន ។ សន្និសីទថ្នាក់រដ្ឋមន្ត្រី GMS ដើរតួជាវេទិកាមួយដើម្បី គូសបញ្ជាក់ពីរបៀបវារៈ បញ្ហាសំខាន់ៗត្រូវពិភាក្សា និងធ្វើសេចក្តីសំរេចលើវិស័យមានការចាប់អារម្មណ៍រួម ។ GMS ក៏មានលក្ខណៈខុសប្លែកនៅត្រង់ថា វាផ្តោតការយកចិត្តទុកដាក់ជាចំបងលើ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំដែនប្រទេស ដើម្បីឆ្លើយតបនឹងកង្វះខាត និងកំរិតអភិវឌ្ឍន៍ទាបនៃហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសជាសមាជិកភាគច្រើន ។ ជាក់ស្តែង គំនិតផ្តួចផ្តើមលើរបៀងសេដ្ឋកិច្ច នឹងបង្កើតបណ្តាញផ្លូវថ្នល់តភ្ជាប់ប្រទេសច្រើន កាត់បន្ថយចំណាយលើការដឹកជញ្ជូន និងសំរួល ដល់ចលនាទំនិញ និងធនធានមនុស្ស ។ មហាអនុតំបន់ទន្លេមេគង្គ ក៏ព្យាយាមដោះស្រាយបញ្ហាផ្នែកទន់ (Software) មួយចំនួន ដូចជា ការសំរួលវិនិយោគទុន និងពាណិជ្ជកម្មឆ្លងព្រំដែន ការអភិវឌ្ឍន៍ធនធានមនុស្សនិងជំនាញ និងការកែលំអនីតិវិធី និងតម្លាភាពនៃការលុបបំបាត់ពន្ធគយ ។ ដូច្នេះ GMS គឺជាកម្មវិធីមួយមានប្រយោជន៍

និងបំពេញបន្ថែម ទៅអោយកិច្ចព្រមព្រៀងបែបតំបន់ ដូចជា អាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ជាពិសេសលើ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។

## ៤.៣ សរុបសេចក្តី

សមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលទៅក្នុងប្រព័ន្ធពាណិជ្ជកម្មបែបតំបន់ និងសាកល អាចផ្តល់ឱកាសដ៏សន្ធឹកសន្ធាប់ដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម តាមរយៈការនាំចេញទៅទីផ្សារអន្តរជាតិ ។ ទោះយ៉ាងនេះក្តី វិស័យកសិកម្មកម្ពុជា ពុំទាន់បានទទួលផលពេញលេញនៅឡើយពីកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មទាំងនេះដោយសារមូលហេតុពីរយ៉ាង ។ ទីមួយ ឧបសគ្គមួយចំនួនជាពិសេសរនាំងមិនមែនពន្ធគយ ដូចជា ឧបត្ថម្ភធន និងតំរូវការធានាគុណភាពទំនិញ នៅតែឃើញមាននៅឡើយក្នុងស្មើររាល់កិច្ចព្រមព្រៀងពាណិជ្ជកម្ម ។ រឿងនេះ ធ្វើឱ្យមានការលំបាកដល់ការនាំចេញពីប្រទេសតូចដូចកម្ពុជា ក្នុងការប្រកួតប្រជែងនៅទីផ្សារអន្តរជាតិ ។ ទីពីរ ផលិតភាព និងសមត្ថភាពប្រកួតប្រជែងនៃវិស័យកសិកម្មកម្ពុជា មានកំរិតទាបដោយសារកំហិតខាងស្ថាប័ន គោលនយោបាយ បច្ចេកទេស និងប្រតិបត្តិការ ។

# ជំពូកទី ៥
# ឧបសគ្គ និងដំណោះស្រាយ

ជំពូកនេះ បកស្រាយអំពីឧបសគ្គផ្សេងៗក្នុងការអភិវឌ្ឍន៍កសិកម្ម និងការធ្វើអាជីវកម្ម/ពាណិជ្ជកម្ម ក្នុងវិស័យនេះដែលធ្វើឱ្យកម្ពុជា ពុំអាចទាញយកចំនេញបានពេញលេញពីការទទួលបានទីផ្សារកសិផល តាមរយៈកិច្ចព្រមព្រៀងផ្សេងៗ ដូចជាកម្មវិធីប្រមូលផលដើមដៃជាដើម ។ ជំពូកនេះក៏មានផ្តល់មតិពីដំណោះស្រាយខាងគោលនយោបាយ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម និងពង្រឹងសមត្ថភាពផ្គត់ផ្គង់ សំដៅចាប់យកឱកាសសេដ្ឋកិច្ចល្អៗ ។

## ៥.១. បញ្ហានានៅក្នុងវិស័យកសិកម្ម និងអាជីវកម្ម

វិស័យកសិកម្ម និងសហគ្រាសជាប់ទាក់ទិននឹងវិស័យនេះ កំពុងជួបប្រទះឧបសគ្គផ្នែកស្ថាប័ន គោលនយោបាយ បច្ចេកទេស និងប្រតិបត្តិការ ។ ឧបសគ្គមួយចំនួន ដូចជា ផ្នែកគោលនយោបាយ ប្រព័ន្ធច្បាប់ ហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាព និងប្រសិទ្ធភាពរបស់រដ្ឋាភិបាល មានលក្ខណៈរួមសំរាប់ផ្នែកផលិត និងអាជីវកម្មក្នុងវិស័យកសិកម្ម រីឯឧបសគ្គខ្លះទៀតមានលក្ខណៈដោយឡែកសំរាប់ផ្នែកនីមួយៗ ។ ឧទាហរណ៍ ផលិតភាពកសិកម្មទាប និងកង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម គឺជាឧបសគ្គចំបងក្នុងការអភិវឌ្ឍន៍កសិកម្ម រីឯកង្វះកំលាំងពលកម្មមានជំនាញ ការអប់រំ និងកង្វះទុន គឺជាបញ្ហាចំបងនៅក្នុងអាជីវកម្ម ។ ទោះបីជាកម្ពុជាទទួលបានទីផ្សារកសិកម្មតាមរយៈកិច្ចព្រមព្រៀងផ្សេងៗក៏ដោយ ក៏វិស័យកសិកម្មកម្ពុជា ពុំទាន់អាចទទួលបានផលប្រយោជន៍ពេញលេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនោះឡើយ ពីព្រោះ កម្ពុជានៅមានឧបសគ្គធំៗជាច្រើនខាងការផ្គត់ផ្គង់ ។ ដោយពាណិជ្ជកម្មកសិផល ពឹងផ្អែកយ៉ាងខ្លាំងនៅលើសមត្ថភាពប្រកួតប្រជែងអន្តរាគមន៍តាមរយៈគោលនយោបាយរដ្ឋ និងវិធានការកែសំរួលឧបសគ្គផ្សេងៗចំពោះកំណើនកសិកម្ម និងអាជីវកម្ម អាចជួយជំរុញការនាំចេញកសិផលកម្ពុជាទៅកាន់ទីផ្សារពិភពលោក និងក្នុងតំបន់ ។

### *៥.១.១. បញ្ហាចំពោះកំណើនកសិកម្ម*

ការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា នៅមានបញ្ហាប្រឈមធំៗនៅឡើយ ។ បញ្ហាទាំងនោះរួមមាន ហេដ្ឋារចនាសម្ព័ន្ធមិនល្អ កង្វះខាតប្រព័ន្ធគោលនយោបាយច្បាស់លាស់និងសមស្រប កង្វះខាតប្រព័ន្ធម៉ាឃីតទីងទីផ្សារល្អ កង្វះខាតបច្ចេកវិទ្យា និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មមិនទាន់គ្រប់គ្រាន់ ។

<u>**ហេដ្ឋារចនាសម្ព័ន្ធ**</u>**:** កង្វះខាតហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដូចជា ប្រព័ន្ធស្រោចស្រព ផ្លូវ និងមធ្យោបាយដឹកជញ្ជូន គឺជាបញ្ហាចំបងមួយក្នុងការបង្កើនផលិតភាពកសិកម្ម និងកំណើនកសិកម្ម (CDRI, 2005) ។

<u>**កង្វះខាតប្រព័ន្ធម៉ាឃីតទីងទីផ្សារល្អ**</u>**:** តាមរយៈ CDRI (2005) គេបានរកឃើញថា យន្តការទីផ្សារដែលសំរួលលំហូរកសិផលពីកសិករទៅកាន់អ្នកប្រើប្រាស់ (ទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិ) ដំណើរការមិនបានល្អទេ ។ កសិករហាក់ដូចមានអំណាចចរចាតិចជាងឈ្មួញកណ្តាល ហើយថ្លៃកសិផលរបស់ពួកគេមានកំរិតទាបជាងក្នុងលក្ខខណ្ឌប្រកួតប្រជែងពេញលេញ ។

រហូតមកដល់បច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា ពុំមានស្ថាប័នម៉ាឃីតទីងទីផ្សារទេ គឺមានតែនាយកដ្ឋានសេវាកម្មព័ត៌មានទីផ្សារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេ (ក្រោមការគាំទ្រពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ) ដែលធ្វើការអភិវឌ្ឍន៍ផ្នែកទីផ្សារ ។

**ផលិតភាពកសិកម្មទាប:** ទិន្នផលស្រូវ និងដំណាំសំរាប់លក់យកប្រាក់ផ្សេងៗក្នុងពេលបច្ចុប្បន្ន នៅមានកំរិតទាបបើធៀបនឹងប្រទេសផ្សេងៗនៅអាស៊ីអគ្នេយ៍ ។ នៅក្នុងតំបន់វាលទំនាបភាគច្រើន ដីពុំសូវមានជីជាតិល្អ គឺជាបញ្ហាចំបងមួយនៅក្នុងផលិតកម្ម ដែលត្រូវដោះស្រាយដោយការគ្រប់គ្រងជីជាតិ និងប្រភេទដី អោយបានសមស្រប ។ កង្វះប្រព័ន្ធស្រោចស្រពរួមផ្សំនឹងដំណើរការប្រព័ន្ធមានស្រាប់ដែលពុំសូវមានប្រសិទ្ធភាព បានបង្អាក់ដំនើរការធ្វើចំរុះកម្មក្នុងផលិតកម្ម ។ ផលិតកម្មកសិកម្មនៅតែប្រឈមមុខនឹងភាពប្រថុយប្រថានខ្ពស់ បើសិនគ្មានការគ្រប់គ្រង និងត្រួតពិនិត្យទឹកឱ្យបានល្អទេ (CDRI, 2005) ។

**សេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្មមិនគ្រប់គ្រាន់:** ការរៀបចំ និងយន្តការក្នុងការផ្តល់សេវាកម្ម គាំទ្របច្ចេកទេសកសិកម្ម ដូចជា កម្មវិធីបំប៉នបច្ចេកទេសបន្ថែម នៅមិនទាន់មាន រឺមានមិនទាន់គ្រប់គ្រាន់ (CDRI, ២០០៥) ។ គេទទួលស្គាល់ជាទូទៅថា សេវាកម្មបំប៉នបន្ថែមផ្នែកបច្ចេកទេសកសិកម្ម នៅទន់ខ្សោយយ៉ាងខ្លាំង ហើយគេមិនទាន់បានបង្កើតឡើងនៅឡើយទេនូវប្រព័ន្ធផ្តល់សេវាកម្មបែបនេះមួយដែលមានលក្ខណៈពេញលេញ ជាពិសេសប្រព័ន្ធសំរាប់ផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្មទៅដល់ប្រជាជនជនបទ ។ បច្ចុប្បន្ននេះ ព័ត៌មានបច្ចេកទេសកសិកម្ម គឺផ្សព្វផ្សាយតាមរយៈបណ្តាញមិនផ្លូវការ ដូចជាកសិករអ្នកជិតខាងគ្នា អង្គការមិនមែនរដ្ឋាភិបាល អ្នកបច្ចេកទេស និងអ្នកចែកចាយវត្ថុធាតុដើមកសិកម្ម ។ លទ្ធភាពកសិករដើម្បីទទួលបាននូវបច្ចេកវិទ្យាទំនើបនៅមានកំរិត ព្រោះសេវាកម្មបំប៉នផ្នែកកសិកម្ម ពុំមែនគាំទ្រដោយការស្រាវជ្រាវ និងអភិវឌ្ឍន៍ទេ (Research & Development) ។ ស្ថាប័នរដ្ឋពុំអាចផ្តល់សេវាកម្មទាំងនេះ និងបំពេញមុខងារអោយបានទាន់ពេល និងទៀងទាត់ ដើម្បីជួយដល់ផលិតកម្មកសិកម្មដែលមានភាពចំរុះ ប្រពលភាព និងមានផលិតភាពកំរិតខ្ពស់ទេ ។

**កង្វះខាតប្រព័ន្ធគោលនយោបាយច្បាស់លាស់:** ការបកស្រាយ និងអនុវត្តន៍ច្បាប់មិនមានលក្ខណៈទៀងទាត់ ហើយទំរង់ការនាំចេញ ក៏មានលក្ខណៈស្មុគស្មាញ និងបង្កបញ្ហា (ធនាគារពិភពលោក ២០០៤) ។ ឧទាហរណ៍ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងឈ្មួញកណ្តាលស្រូវនៅភាគពាយព្យប្រទេស បានបង្ហាញពីការលំបាក និងការចំណាយប្រាក់អស់ច្រើន ដើម្បីទទួលបានអាជ្ញាប័ណ្ណសំរាប់ការនាំចេញ ។ ជាងនេះទៅទៀត ច្បាប់ទំលាប់ជាច្រើនមិនមានលក្ខណៈអំណោយផលដល់ការនាំចេញជាលក្ខណៈស្របច្បាប់ទេ ។ ជាលទ្ធផល ការនាំចេញកសិផលភាគច្រើន មានលក្ខណៈមិនស្របច្បាប់ ។

### *៥.១.២. បញ្ហាចោទចំពោះប្រតិបត្តិការ និងកំណើនអាជីវកម្ម*

សហគ្រាសនៅក្នុងប្រទេសកម្ពុជាកំពុងជួបប្រទះបញ្ហាចំបងៗ រួមមានទាំងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ស្ថាប័នរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ។ បញ្ហាទាំងនេះបានធ្វើអោយ សហគ្រាសទាំងនោះពិបាកពង្រីកសមត្ថភាពប្រកួតប្រជែង ។

**អំពើពុករលួយ:** គេបានរកឃើញថា វាជាឧបសគ្គចំបងចំពោះអាជីវកម្មនៅកម្ពុជា[៧] ។ វាជាកត្តាបង្អាក់ដល់ការវិនិយោគ ដោយបង្កើននូវចំណាយផ្សេងៗដោយមិនចំហ ។ គេតែងលើកថា អំពើពុករលួយកើតមានពាសពេញ ជាពិសេសទាក់ទងនឹងការសុំលិខិតអនុញ្ញាតនាំចេញនាំចូល សេចក្តីសំរេចចិត្តរបស់តុលាការ និងការទទួលបានកិច្ចសន្យាម៉ៅការសាធារណៈ ។ វាក៏កើតមានឡើងជាទូទៅក្នុងសកម្មភាពអាជីវកម្មផ្សេងៗទៀត ដូចជា ការតភ្ជាប់នឹងសេវាកម្មផ្គត់ផ្គង់សាធារណៈ និងការ

---

(៧) ទាំងការស្ទាបស្ទង់មតិលើបរិយាកាសវិនិយោគទុនរបស់ធនាគារពិភពលោក និងការស្ទាបស្ទង់មតិរបស់ថ្នាក់ដឹកនាំឆ្នាំ២០០៥ របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានបង្ហាញថា អំពើពុករលួយ គឺជាកត្តាដែលចោទបញ្ហាធំជាងគេសំរាប់អាជីវកម្ម ។

បង់ពន្ធជាដើម (EIC, 2005) ។

**ស្ថាប័នរដ្ឋពុំសូវមានប្រសិទ្ធភាព:** គេយល់ថា នេះក៏ជាឧបសគ្គចំបងមួយដែរ ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ២០០៤ "ការិយាធិបតេយ្យរបស់ប្រទេសកម្ពុជា មានទាក់ទិននឹងនយោបាយ មានលក្ខណៈសំពីងសំពោង និងពុំមានប្រសិទ្ធភាព ហើយរឿងនេះបង្កើតបញ្ហាដល់ទាំងអាជីវកម្មដែលមានស្រាប់ និងអាជីវកម្មដែលអាចកើតមាន" ។ កង្វះអភិបាលកិច្ចល្អ និងតម្លាភាព ក៏ឃើញមានច្រើននៅក្នុងចំណោមស្ថាប័នសាធារណៈដែរ ។ ស្ថាប័នសាធារណៈរបស់កម្ពុជាស្ថិតក្នុងប្រភេទទន់ខ្សោយជាងគេបង្អស់នៅលើពិភពលោក ហើយខ្សោយក្នុងផ្នែកពីរគឺៈ ការអនុវត្តន៍ច្បាប់និងកិច្ចសន្យា និងអភិបាលកិច្ច/តម្លាភាព ។ ប្រព័ន្ធតុលាការពុំមានភាពឯករាជ្យពីឥទ្ធិពលខាងក្រៅទេ ហើយក្របខ័ណ្ឌច្បាប់ ក៏ពុំមានប្រសិទ្ធភាពសំរាប់ដោះស្រាយវិវាទអាជីវកម្ម ឬសំរាប់ដេញដោលភាពស្របច្បាប់នៃសកម្មភាពរដ្ឋាភិបាលដែរ ។

**កង្វះខាតធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត:** នេះក៏ជាបញ្ហាចំបងមួយដែរ ។ ជាលទ្ធផលនៃការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម និងទំនាស់ច្រើនទសវត្សរ៍ ធនធានមនុស្សសំរាប់វិស័យឯកជន និងសាធារណៈគឺមានតិចតួចណាស់ ។ ក្រៅពីកង្វះខាតទុន និងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក៏នៅខ្វះខាតយ៉ាងខ្លាំងដែរ ។ អាំងឌីកាទ័របង្ហាញពីដង់ស៊ីតេផ្លូវ ដង់ស៊ីតេទូរគមនាគមន៍ អគ្គិសនី និងទឹកនៅកម្ពុជា ស្ថិតនៅក្នុងចំណោមប្រទេសដែលអន់ខ្សោយជាងគេបំផុតនៅលើពិភពលោក (ធនាគារពិភពលោក ២០០៤) ។ អង្កេតរបស់ EIC ទៅលើទស្សនៈរបស់ថ្នាក់ដឹកនាំក្រុមហ៊ុនឯកជន ក៏បានរកឃើញលទ្ធផលដូចគ្នានេះដែរ ។ បើតាមការសិក្សានេះ ៨៥% នៃថ្នាក់ដឹកនាំក្រុមហ៊ុនឯកជនដែលបានឆ្លើយសំភាសន៍យល់ឃើញថា សេវាកម្មសាធារណៈមានតំលៃខ្ពស់ និងមានការរអាក់រអួលជាញឹកញាប់ ហើយផ្លូវដែក កំពង់ផែ ព្រមទាំងប្រព័ន្ធដឹកជញ្ជូនផ្លូវទឹកក្នុងប្រទេស ក៏ពុំទាន់បានអភិវឌ្ឍល្អ ។ ទោះបីជាបច្ចេកទេសទំនាក់ទំនងទូរស័ព្ទចល័ត ត្រូវបានទទួលស្គាល់ថា ជាប់លំដាប់ថ្នាក់ពិភពលោកក្តី ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធសាធារណៈភាគច្រើន ត្រូវបានគេយល់ថានៅពុំទាន់អភិវឌ្ឍបានល្អទេ ។

**កង្វះខាតទុន:** នេះជាបញ្ហាមួយទៀតនៅក្នុងអាជីវកម្ម ។ ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកកំពុងស្ថិតនៅក្នុងដំណាក់កាលក្មេងខ្ចី និងមានកំរិតលូតលាស់នៅទាប ឆ្ងាយពីស្ថាប័នហិរញ្ញវត្ថុ និងធនាគារពិភពលោក ទាំងផ្នែកសេវាកម្ម និងផលិតផល (EIC, 2005) ។ ប្រទេសកម្ពុជាគ្មានផ្សារហ៊ុន សំរាប់ប្រមូលទុនវិនិយោគទេ ។ បើសិនជាគ្រាន់តែមានផែនការអាជីវកម្មល្អ តែគ្មានរបស់បញ្ចាំ អ្នកខ្ចីមានការពិបាក រឺមិនអាចខ្ចីទុនពីធនាគារបានទេ ។

**ភាពមិនទៀងទាត់នៃច្បាប់ និងទំងន់នៃកាតព្វកិច្ចខាងផ្លូវច្បាប់:** រឿងនេះក៏ជាបញ្ហាសំខាន់ដែរនៅក្នុងសហគ្រាស និងអាជីវកម្ម ។ ការបកស្រាយ និងអនុវត្តន៍ច្បាប់ ពុំមានលក្ខណៈទៀងទាត់ ។ ៧៦% នៃក្រុមហ៊ុនដែលបានអង្កេតយល់ថា ច្បាប់ និងគោលនយោបាយរដ្ឋដែលប៉ះពាល់ដល់ពួកគាត់ គឺមិនអាចប្រមើលទុកបានទេ (ធនាគារពិភពលោក ២០០៤) ។ ជាងនេះទៅទៀត ច្បាប់មួយចំនួនដូចជាៈ ពន្ធគយ និងពាណិជ្ជកម្ម ការចុះបញ្ជីអាជីវកម្ម សវនកម្មអាជីវកម្ម ច្បាប់បរិស្ថាន និងច្បាប់ការងារបានដាក់កំហិតច្រើនខ្លាំងណាស់លើអ្នកនាំចេញ បើធៀបនឹងផលិតករសំរាប់ទីផ្សារក្នុងស្រុក ។

## ៥.២. អនុសាសន៍ចំពោះគោលនយោបាយ

### *៥.២.១. អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា*

ដើម្បីអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ការដោះស្រាយឧបសគ្គទូទៅនៅក្នុងវិស័យនេះគឺជាការចាំបាច់ ដោយត្រូវផ្តល់កិច្ចប្រឹងប្រែង និងធនធានបន្ថែមទៀត ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន សេវាកម្មបំប៉នបន្ថែម និងស្ថាប័នសាធារណៈប្រកបដោយប្រសិទ្ធភាព ។ ម្យ៉ាងទៀត ក៏គួរផ្តោតការយកចិត្តទុកដាក់លើផលិតផលកសិកម្មដែលមានសក្តានុពលខ្ពស់សំរាប់ទីផ្សារ

ប្រទេសចិនដែរ ។

*ការផ្តល់បរិយាកាសអំណោយផល*

ពិតណាស់ ប្រទេសកម្ពុជាត្រូវការបរិស្ថានដែលអំណោយផលដល់វិស័យកសិកម្ម ។ ស្ថាប័នសាធារណៈ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រាន់ ក្របខ័ណ្ឌគោលនយោបាយល្អ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ជាធាតុសំខាន់ បង្កអោយមានបរិយាកាសអំណោយផល ។ រដ្ឋាភិបាលគួរខិតខំប្រឹងប្រែង និងចាត់វិធានការពង្រឹងបរិយាកាសអោយកាន់តែអំណោយផល រីឯម្ចាស់ជំនួយ ក៏គួរផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសបន្ថែមទៀតទៅអោយរដ្ឋាភិបាល រួមទាំងការពិនិត្យមើលដំណើរការ និងលទ្ធផល ។

*បង្កើតតំបន់អភិវឌ្ឍន៍កសិកម្មពិសេស* **(SADZ)**

ការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្មពិសេស ជាអនុសាសន៍មួយនៅក្នុងការសិក្សាអំពី "ការពង្រឹងប្រព័ន្ធម៉ាឃីតទីងនៃកសិផលពោត និងសណ្តែកសៀងនៅកម្ពុជា" (CDRI, 2005) ។ ការបង្កើតតំបន់អភិវឌ្ឍន៍ពិសេស ជួយអោយគេអាចអភិវឌ្ឍផលិតផលជាក់លាក់ទៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ។ យុទ្ធសាស្ត្រតំបន់អភិវឌ្ឍន៍កសិកម្មពិសេសនេះ មានចំណុចខ្លាំងមួយចំនួន បើធៀបនឹងយុទ្ធសាស្ត្រធម្មតា ។ ទីមួយ SADZ អនុញ្ញាតអោយរដ្ឋ ផ្តោតកំលាំងទៅលើតំបន់ជាក់លាក់ ដោយបែងចែកធនធាន និងការគ្រប់គ្រងទៅលើតំបន់តូចៗ ដើម្បីទទួលបានលទ្ធផលច្រើនជាអតិបរមា ជាជាងផ្តោតការយកចិត្តទុកដាក់ទៅទូទាំងប្រទេសដែលមានភាពរប៉ាត់រប៉ាយ និងពិបាកគ្រប់គ្រង ។ ទីពីរ យុទ្ធសាស្ត្រ SADZ នេះ ងាយគ្រប់គ្រង តាមដាន កែតំរូវ ព្រមទាំងជួយបង្កើតហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលចាំបាច់ដូចជា ការរកទីផ្សារល្អ ការស្តុកទុក ការដឹកជញ្ជូន និងការកែច្នៃផលិតផល ។ ទីបី វាជាដំណើរការអភិវឌ្ឍន៍មួយមានភាពជាក់ស្តែង ដែលអាចទាក់ទាញអង្គការ ឬស្ថាប័ន ឬអ្នកចាប់អារម្មណ៏ផ្សេងៗអោយចូលរួមរៀនសូត្រ តាមរយៈការអនុវត្តន៏ជាក់ស្តែង នៅក្នុងការសហការអភិវឌ្ឍន៏តំបន់នេះ ។

*លើកទឹកចិត្តអោយមានការចូលរួមពីវិស័យឯកជន (ដោយមានការគាំទ្រពីម្ចាស់ជំនួយ)*

ដើម្បីកសាងតំបន់អភិវឌ្ឍន៏កសិកម្មពិសេស គេចាំបាច់ត្រូវបង្កើតក្របខ័ណ្ឌ និងច្បាប់ស្តីពីការរកស៊ីចូលហ៊ុន (Joint Venture) ។ ដោយប្រឈមនឹងការប្រថុយប្រថាននានា វិនិយោគិនសក្តានុពលទាមទារឱ្យមានការធានាខាងរដ្ឋបាលជាចាំបាច់ ។ រាជរដ្ឋាភិបាលអាចអញ្ជើញប្រទេសផ្សេងៗ ឱ្យចូលរួមបង្កើតក្របខ័ណ្ឌនេះ ឬអនុវត្តក្របខ័ណ្ឌដែលមានស្រាប់ទៅក្នុងតំបន់អភិវឌ្ឍន៏កសិកម្មគោលដៅ ។ នៅក្នុងដំណើការនេះ ការចូលរួមពីផ្នែកឯកជន គឺជាការចាំបាច់ដោយខានពុំបាន ។ ដោយស្ថានភាពអាជីវកម្មបច្ចុប្បន្ន និងការអភិវឌ្ឍន៏កសិកម្ម នៅកម្ពុជាពុំទាន់មានលក្ខណៈល្អប្រសើរ កម្ពុជាមានជំរើសតិចតួចណាស់ក្រៅពីស្វែងរកយុទ្ធសាស្ត្រសហប្រតិបត្តិការណាមួយដែលអាចបង្កើតអោយមានការអភិវឌ្ឍន៏អាជីវកម្មនោះ ។ ការបង្វែរទិសដែលមានលក្ខណៈយុទ្ធសាស្ត្របែបនេះ គឺជាធាតុមួយដ៏សំខាន់បំផុតនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៏អាជីវកម្ម និងការអនុវត្តន៏តំបន់អភិវឌ្ឍន៏កសិកម្មពិសេស ។ កម្ពុជាអាចស្វែងរកជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីអ្នកផ្តល់ជំនួយធំៗដូចជា ធនាគារអភិវឌ្ឍន៏អាស៊ី ប្រទេសចិន សហព័ន្ធអឺរ៉ុប និងដៃគូពាណិជ្ជកម្មធំៗផ្សេងទៀត ដែលប្រាថ្នាចង់មានទំនាក់ទំនងសេដ្ឋកិច្ចល្អយូរអង្វែងជាមួយកម្ពុជា ។

### *៥.២.២. ការកសាងសមត្ថភាពផ្គត់ផ្គង់ និងប្រកួតប្រជែង*

UNESCAP ២០០៤ បានបង្កើតដ្យាក្រាមមួយអំពីការកសាងសមត្ថភាពផ្គត់ផ្គង់ដោយកំណត់ក្របខ័ណ្ឌ ច្បាប់ និងគោលនយោបាយជំរុញប្រសិទ្ធភាពស្ថាប័នរដ្ឋនិងអភិបាលកិច្ចល្អ ថាជាស្រទាប់ទី១ រីជាគ្រឹះ ឯការអប់រំទូទៅ និងហេដ្ឋារចនាសម្ព័ន្ធជាស្រទាប់ទីពីរ ។ ធាតុទាំងនេះ គឺជាគន្លឹះដែលអាចជួយគាំទ្រដល់វិធានការចាំបាច់ផ្សេងទៀត សំរាប់បង្កើនផលិតភាព រួមមាន

ការទទួលបានទុន សេវាកម្មគាំទ្រអាជីវកម្ម ជំនាញគ្រប់គ្រង និងបច្ចេកទេស ព្រមទាំងពង្រីកបណ្តាញផ្សេងៗ ឆ្ពោះទៅកាន់ការផ្គត់ផ្គង់ទៅក្នុងទីផ្សារពិភពលោក ។ មូលដ្ឋានទាំងនេះក៏អាចជួយសំរួលដល់វិធានការផ្សេងៗ សំរាប់កាត់បន្ថយចំណាយក្នុងការធ្វើពាណិជ្ជកម្មដែរ ដូចជា ទំរង់ការ និងការរត់ការឯកសារល្អ ការកែលំអបច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ និងដឹកជញ្ជូន ព្រមទាំងព័ត៌មានទីផ្សារ ។ ដូចនេះ ដើម្បីបង្កើនសមត្ថភាពផ្គត់ផ្គង់ និងប្រកួតប្រជែង គេចាំបាច់ត្រូវពង្រឹងមូលដ្ឋានគ្រឹះ បង្កើនសមត្ថភាពផលិតកម្ម និងកាត់បន្ថយចំណាយក្នុងការធ្វើពាណិជ្ជកម្ម ។

*ពង្រឹងមូលដ្ឋានគ្រឹះ:*

គេតែងតែយល់ស្របជាទូទៅថា កំណែទំរង់មួយចំនួនដូចជា រដ្ឋបាលសាធារណៈ ច្បាប់ និងប្រព័ន្ធតុលាការ ហិរញ្ញវត្ថុ និងធនាគារ គឺជាការចាំបាច់នៅក្នុងសហគមន៍អាជីវកម្ម ។ លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចគួរតែអភិវឌ្ឍថែមទៀត ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់វិស័យឯកជន ។ ការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់ ផ្លូវល្អ ផ្លូវដែក កំពង់ផែ បណ្តាញព័ត៌មាន និងទំនាក់ទំនង ផ្តល់នូវមូលដ្ឋានគ្រឹះដល់ការប្រាស្រ័យទាក់ទង និងការដឹកជញ្ជូនល្អប្រសើរ ហើយមានសារៈសំខាន់ខ្លាំងណាស់ចំពោះវិស័យឯកជនដែលមានលក្ខណៈប្រកួតប្រជែងអន្តរជាតិ ។

*បង្កើនសមត្ថភាពផលិត :*

រដ្ឋាភិបាលអាចចាត់វិធានការមួយចំនួនសំរាប់ពង្រឹងសមត្ថភាពផលិតរបស់សហគ្រាសដូចជា :

- ជំរុញការផ្តល់សេវាកម្មអាជីវកម្មរបស់វិស័យឯកជន
- លើកទឹកចិត្ត និងតាមដានការអោយខ្ចីរបស់ធនាគារពាណិជ្ជ ទៅអោយក្រុមហ៊ុន ជាពិសេស សហគ្រាសខ្នាតតូច និងមធ្យម និងលើកទឹកចិត្តដល់ការបង្កើតការិយាល័យឥណទាន និងការធ្វើជាដៃគូរវាងអ្នកផ្តល់សេវាកម្ម អភិវឌ្ឍន៍អាជីវកម្ម និងអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ ។
- បង្កើតយន្តការ ដើម្បីធានាអោយមានអភិបាលកិច្ចល្អ
- ជំរុញ និងសំរួលវិនិយោគផ្ទាល់ពីបរទេស ។ បង្កើតយន្តការផ្សេងៗ ដើម្បីពង្រឹងសម្ព័ន្ធទំនាក់ទំនងផ្នែកផ្គត់ផ្គង់ និងតំរូវការរវាងសហគ្រាសបរទេស និងក្នុងស្រុក ព្រមទាំងរវាងសហគ្រាសខ្នាតធំ និងខ្នាតតូចក្នុងស្រុក ។

*កាត់បន្ថយចំណាយក្នុងការធ្វើពាណិជ្ជកម្ម*

វិធានការជួយសំរួលពាណិជ្ជកម្មដូចមានចែងក្នុងផែនការ ១២ចំណុចរបស់រដ្ឋាភិបាល ដើម្បីពង្រឹងបរិយាកាសវិនិយោគទុន និងសំរបសំរួលពាណិជ្ជកម្ម គួរតែអនុវត្តន៍អោយបានខ្ជាប់ខ្ជួន ។ វិធានការណ៍មួយចំនួនគួរតែផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់ ដូចជា ការកែសំរួលទំរង់ការ បែបបទនិងច្បាប់ពន្ធគយ និងពាណិជ្ជកម្ម ការធ្វើអោយមានភាពសាមញ្ញ និងស៊ីគ្នាក្នុងការរត់ការឯកសារពាណិជ្ជកម្ម និងការបំពាក់គ្រឿងកុំព្យូទ័រនិងទំនើបកម្ម នៅក្នុងទំរង់ការពន្ធគយ និងពាណិជ្ជកម្ម ។ អនុសាសន៍ផ្សេងទៀតមានដូចជា ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពាណិជ្ជកម្ម គួរតែអភិវឌ្ឍន៍ ដើម្បីជួយអោយក្រុមហ៊ុន ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យម អាចផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ប្រតិបត្តិការ ពាណិជ្ជកម្ម និងអាចគ្រប់គ្រងហានិភ័យដែលអាចកើតមាន ។

### *៥.២.៣. ការកសាងសហប្រតិបត្តិការសេដ្ឋកិច្ច និងអាជីវកម្មជាមួយចិន*

រដ្ឋាភិបាលគួរស្វែងរកជំនួយបច្ចេកទេសពីប្រទេសចិន ដើម្បីអភិវឌ្ឍផលិតកម្ម និងផលិតភាពកសិកម្ម ដោយផ្តោតទៅលើផលិតផលដែលមានសក្តានុពលខ្ពស់សំរាប់ការនាំចេញទៅចិន ។ រដ្ឋាភិបាលគួរតែចរចាអោយចិនលើកលែងរបាំង មិនមែនពន្ធគយមួយចំនួន ដើម្បីអោយកសិផលកម្ពុជា ងាយបំពេញបានតាមល័ក្ខខ័ណ្ឌនាំចេញដែលមានតំរូវឡើង ។ ក្រៅពីនេះ

រដ្ឋាភិបាល ក៏ដូចជាសមាគមអាជីវកម្ម ត្រូវបង្កើនទំនាក់ទំនងអាជីវកម្មជាមួយចិន ។ សហគ្រាសកម្ពុជា ក៏អាចទទួលបានប្រយោជន៍ជាព័ត៌មានទីផ្សារ បច្ចេកទេសម៉ាឃីតទីង និងប្រកួតប្រជែង ពីការផ្លាស់ប្តូរទស្សនកិច្ចយ៉ាងទៀងទាត់ ការបង្កើតការិយាល័យតំណាងនៅចិន និងជំនួយផ្សេងទៀតពីសមាគមអាជីវកម្មនៅប្រទេសចិន ។ ប្រទេសទាំងពីរអាចធ្វើការរួមគ្នាដើម្បីសំរួលការបង្កើតបណ្តាញទាំងនេះ ។

# ជំពូកទី ៦
# សេចក្តីសន្និដ្ឋាន

កម្មវិធីប្រមូលផលដើមដៃ ក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងអំពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងអាស៊ាន និងចិន បានធ្វើឡើងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងព្យាយាមអភិវឌ្ឍវិស័យកសិកម្ម តាមរយៈពាណិជ្ជកម្មក្នុងតំបន់ និងក្នុងពិភពលោក ។ កម្មវិធីប្រមូលផលដើមដៃនេះ ក៏បានផ្តល់អោយកម្ពុជានូវក្តីសង្ឃឹមយ៉ាងមាំក្នុងការអភិវឌ្ឍន៏វិស័យកសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈឱកាសសំរាប់នាំចេញផលិតផលមួយចំនួនដូចជា ផ្លែឈើស្រស់ ត្រី សាច់ បង្គា ជាដើម ឆ្លងតាមបទពិសោធន៏ពីបណ្តាប្រទេសផ្សេងៗ ដូចជា ថៃ ជាដើម ។ ប៉ុន្តែសហគ្រិន នឹងមិនអាចទទួលបានប្រយោជន៏ និងឱកាសថ្មីៗទាំងនេះទេ បើសិនជាគ្មានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បរិយាកាសអាជីវកម្មដែលអំណោយផល ក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធល្អ និងស្ថាប័នរដ្ឋដែលមានប្រសិទ្ធភាព ។ កម្ពុជានៅមិនទាន់បំពេញលក្ខខ័ណ្ឌទាំងនេះបានទេ ។ ដូចនេះ វិស័យកសិកម្ម និងសហគ្រាសនៅក្នុងប្រទេស ត្រូវជួបឧបសគ្គមួយចំនួនក្នុងផ្នែកស្ថាប័នគោលនយោបាយ បច្ចេកទេស និងការប្រតិបត្តិ ។

ដើម្បីអោយកម្ពុជាទទួលបានប្រយោជន៏ច្រើនពីកម្មវិធីប្រមូលផលដើមដៃ គេគួរដោះស្រាយរាល់ឧបសគ្គដែលរាំងស្ទះដល់ការអភិវឌ្ឍន៏វិស័យកសិកម្ម និងការបង្កើនសមត្ថភាពផ្គត់ផ្គង់ ។ កំណែទំរង់ផ្នែករដ្ឋបាល ច្បាប់ និងប្រព័ន្ធតុលាការ គួរតែធ្វើឡើងដើម្បីអោយស្ថាប័នសាធារណៈមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងកាត់បន្ថយអំពើពុករលួយ ។ ម្យ៉ាងទៀត ដើម្បីអោយបរិយាកាសពាណិជ្ជកម្មកាន់តែអំណោយផលល្អ ច្បាប់ទំលាប់ គោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមគួរតែកែលំអ ។ គេក៏ឃើញមានតំរូវការបន្ទាន់ក្នុងការពង្រឹងផលិតភាពកសិកម្ម សមត្ថភាពប្រកួតប្រជែង និងបង្កើនសមត្ថភាពផលិតរបស់សហគ្រាស ព្រមទាំងកាត់បន្ថយចំណាយក្នុងការធ្វើពាណិជ្ជកម្ម ជាពិសេសតាមរយៈវិធានការសំរួលពាណិជ្ជកម្ម ។ ទន្ទឹមនេះ គួរមានអន្តរាគមន៏ខាងគោលនយោបាយយ៉ាងមុតមាំ ដើម្បីអភិវឌ្ឍផលិតផលកសិកម្មដែលមានសក្តានុពលខ្ពស់ សំរាប់ការនាំចេញទៅចិនតាមរយៈកម្មវិធីប្រមូលផលដើមដៃ ។ កំណើនជំនួយអភិវឌ្ឍន៏ និងជំនួយបច្ចេកទេសពីប្រទេសចិន និងការសហការកាន់តែជិតស្និទរវាង សមាគមអាជីវកម្មនៅក្នុងប្រទេសទាំងពីរ គឺមានសារៈសំខាន់ និងការចាំបាច់បំផុតសំរាប់ ជំរុញពាណិជ្ជកម្ម ។

ដើម្បីអោយកម្មវិធីប្រមូលផលដើមដៃមានឥទ្ធិពលកាន់តែច្រើនទៅលើការកាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលគួរតែជំរុញការចូលរួមរបស់ជនក្រីក្រនៅក្នុងកំណើនសេដ្ឋកិច្ច និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ គេគួរមានវិធានការសមស្របសំរាប់ដោះស្រាយឥទ្ធិពលអវិជ្ជមានដែលអាចកើតមានចំពោះអ្នកក្រីក្រ ។ អនាគតនៃវិស័យកសិកម្ម និងផលប្រយោជន៏នៃកម្មវិធីប្រមូលផលដើមដៃនៅក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ពឹងផ្អែកទៅលើជោគជ័យនៃគោលនយោបាយរដ្ឋ និងកម្មវិធីកំណែទំរង់ផ្សេងៗ ក្នុងការពង្រឹង និងអភិវឌ្ឍន៏វិស័យកសិកម្ម និងសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសនៅកម្ពុជា ។

# ឯកសារយោង

_____ (2002), *Framework Agreement on Comprehensive Economic Cooperation Between The Association of South East Asian Nations and The People's Republic of China* (Jakarta: ASEAN Secretariat)

Appleyard, Dennis & Alfred Field (2001), *International Economics* (Singapore: McGraw Hill)

ASEAN-China Expert Group on Economic Cooperation (2001), *Forging Closer ASEAN-China Economic Relations in the Twenty-First Century* (Jakarta: ASEAN Secretariat).

Bernardino, Natividad Y. (2004), *The ASEAN-China Free Trade Area: Issues and Prospects* (Manila: International Gender & Trade Network)

Cambodia Development Resource Institute (2005), *Annual Development Review 2004–2005* (Phnom Penh: CDRI)

Chia Siow Yue (2004), *ASEAN-China Free Trade Area*, Paper presented at the AEP Conference, Hong Kong, 12–13 April 2004 (Singapore: Singapore Institute of International Affairs)

Cordenillo, Raul L. (2005), *The Economic Benefits for ASEAN of the ASEAN-China Free Trade Area (ACFTA)* (Jakarta: ASEAN Secretariat)

Economic Institute of Cambodia (2005), *Cambodia Competitiveness Report 2005* (Phnom Penh: EIC)

Kanokpan Lao-Araya (2002), *How Can Cambodia, Lao PDR, Myanmar and Vietnam Cope with Revenue Lost Due to AFTA Tariff Reduction?*, ERD Working Paper No.29 (Manila: Asian Development Bank)

Li Wei (2004), *Progress of China-ASEAN FTA and Implications for East Asian FTA* (Seoul: Chinese Academy of International Trade and Economic Cooperation)

Medhi Krongkaew (2004), "The Development of the Greater Mekong Subregion (GMS): Real Promise or False Hope?" *Journal of Asian Economics* 15 (2004) pp. 977-998

Thitapha Wattanapruttipaisan (2002), *The Newer ASEAN Member Countries and ASEAN-China FTA: Additional Market Access and More Challenging Competition* (Jakarta: ASEAN Secretariat)

Toshiyasu K., Chan.S, and Long P. (1998), *Regional Economic Integration for Sustainable Development in Cambodia*, Working Paper 5 (Phnom Penh: CDRI).

United Nations Economic and Social Commission for Asia and the Pacific (2004), *Addressing Supply-side Constraints and Capacity-Building* (Bangkok: UNESCAP)

Wong, John & Sarah Chan, *China-ASEAN Free Trade Arrangement: Opportunities and Challenges* (China: TCDC Network)

World Bank (2004), *Seizing the Global Opportunity: Investment Climate Assessment & Reform Strategy*, prepared for the Royal Cambodian Government by the World Bank Group. (Phnom Penh: World Bank)

World Bank (2006), *Cambodia: Halving poverty by 2015?* Poverty Assessment 2006, prepared by the World Bank for the Consultative Group Meeting. (Phnom Penh: World Bank)

# ឧបសម្ព័ន្ធ

ការប្តេជ្ញាចិត្តសំខាន់ៗមួយចំនួនដែលមានចែងនៅក្នុងរបាយការណ៍ក្រុមការងារ ស្តីពីការបញ្ចូលកម្ពុជាក្នុង WTO (WT/ACC/KHM/21) គឺ ៖

- *កម្មសិទ្ធិរដ្ឋ និងឯកជនភាវូបនីយកម្ម:* កម្ពុជា នឹងធានាអោយមានតម្លាភាព អោយដំណឹងដល់សមាជិក WTO និងផ្តល់របាយការណ៍ទៀងទាត់អំពីបញ្ហាផ្សេងៗទាក់ទិននឹងកំណែទំរង់សេដ្ឋកិច្ចដែលតំរូវអោយធ្វើ ។
- *គោលនយោបាយកំណត់ថ្លៃ:* កម្ពុជា នឹងអនុវត្តការត្រួតពិនិត្យថ្លៃអោយស្របតាម WTO ហើយនឹងគិតគូរពីផលប្រយោជន៍នៃប្រទេសនាំចេញដែលជាសមាជិក WTO ។ កម្ពុជា និងចុះផ្សាយបញ្ជីទំនិញ និងសេវាកម្មដែលនឹងត្រូវត្រួតពិនិត្យថ្លៃដោយរដ្ឋ ។
- *សិទ្ធិធ្វើពាណិជ្ជកម្ម:* ឆ្លើយតបទៅនឹងសេចក្តីអធិប្បាយថា ការដាក់កំរិតលើការនាំចូលថ្នាំពេទ្យ និងថ្នាំព្យាបាលសត្វអាចក្លាយជាការរើសអើងដើម្បីជួយដល់ផលិតផលដូចគ្នាដែលផលិតក្នុងស្រុក កម្ពុជាបានបញ្ជាក់ថា ខ្លួននឹងធ្វើវិសោធនកម្មច្បាប់នេះ ហើយធានាថា វិធាន និងច្បាប់ទាំងឡាយ នឹងស្របតាមកាតព្វកិច្ចរបស់ខ្លួនចំពោះ WTO មិនយូរជាងថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៥ ។
- *ការយកកំរៃ និងពន្ធគយផ្សេងទៀត:* កម្ពុជា នឹងធានាអោយការយកកំរៃ និងពន្ធគយទាំងនេះស្របទៅតាមបញ្ញត្តិ WTO ចាប់ពីថ្ងៃចូលជាសមាជិក ហើយនឹងត្រូវបញ្ចុះឱ្យដល់កំរិតសូន្យ ។
- *កូតាអត្រាពន្ធគយ និងការលើកលែងពន្ធគយ:* កម្ពុជាបានបញ្ជាក់ថា ខ្លួននឹងគោរពតាមវិន័យ WTO លើកូតាអត្រាពន្ធគយ ។ កម្ពុជាក៏បានបញ្ជាក់ថា រាល់ការលើកលែងពន្ធគយ នឹងធ្វើឡើងអោយស្របទៅនឹងបញ្ញត្តិ WTO ។
- *កំរៃ និងការយកថ្លៃសេវាកម្ម:* រាល់កំរៃ និងការយកថ្លៃលើសេវាកម្មទាក់ទិនដល់ការនាំចេញនាំចូល នឹងស្របតាមកិច្ចព្រមព្រៀង WTO ។ ចាប់ពីថ្ងៃចូលជាសមាជិក WTO កម្ពុជានឹងមិនអនុវត្ត ឬណែនាំអោយប្រើ ឬដាក់អោយមានឡើងវិញនូវរាល់កំរៃ និងការយកថ្លៃលើសេវាកម្មដែលអនុវត្តលើអត្រានាំចូល (ជាភាគរយនៃថ្លៃនាំចូល) ។
- *ពន្ធក្នុងស្រុក:* ចាប់ពីថ្ងៃចូលសមាជិក កម្ពុជានឹងអនុវត្តពន្ធក្នុងស្រុកអោយស្របតាមមាត្រាទី ៣ នៃ GATT និងក្នុងលក្ខណៈមិនរើសអើងចំពោះផលិតផលនាំចូល ។ មាត្រាទី ៣ ចែងអំពី "ប្រព្រឹត្តិកិច្ចជាតិ" (ឬការមិនរើសអើងរវាងផលិតផលក្នុងស្រុក និងផលិតផលមកពីបរទេស) លើការយកពន្ធ ។
- *ការកំណត់បរិមាណនាំចូល ដែលរួមមានប្រព័ន្ធហាមឃាត់ កូតា និងការផ្តល់អាជ្ញាប័ណ្ណ:* មិនអោយយឺតជាងថ្ងៃទី ១ មិថុនា ២០០៥ កម្ពុជា នឹងលុបចោលការកំណត់បរិមាណលើការនាំចូលលើជី ថ្នាំសំលាប់សត្វល្អិត និងវត្ថុធាតុដើមកសិកម្មផ្សេងទៀត ហើយនឹងបង្កើតអោយមាននិតិវិធីចុះបញ្ជី និងការត្រួតពិនិត្យសារធាតុគីមីកសិកម្មអោយស្របតាម WTO ។ ពីថ្ងៃទី ១ មករា ២០០៧ កម្ពុជា នឹងផ្អែកលើបញ្ញត្តិនៃកិច្ចព្រមព្រៀងរបាំងបច្ចេកទេសលើពាណិជ្ជកម្ម ដើម្បីចាត់វិធានច្បាប់លើពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ ។ បន្ទាប់ពីចូលជាសមាជិក WTO កម្ពុជានឹងមិនណែនាំពន្ធគយអោយប្រើប្រាស់ ឬដាក់អោយប្រើប្រាស់ឡើងវិញ ឬអនុវត្តវិធានការមិនមែនពន្ធគយផ្សេង

ទៀត ដូចជាការសុំអាជ្ញាប័ណ្ណ ការកំណត់កូតា ការហាមឃាត់ និងការរិតត្បិតមានឥទ្ធិពលស្មើផ្សេងទៀត ដែលមិនស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ។

- *ការវាយតំលៃពន្ធគយ:* កម្ពុជា នឹងអនុវត្តន៍យ៉ាងពេញទំហឹងនូវកិច្ចព្រមព្រៀងវាយតំលៃពន្ធគយ ចាប់ពីថ្ងៃទី ១ មករា ២០០៩ ។
- *ច្បាប់ប្រភពដើម:* កម្ពុជា នឹងគោរពយ៉ាងលេញតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងច្បាប់ប្រភពដើមរបស់ WTO ពីថ្ងៃទី ១ មករា ២០០៥ ហើយគោរពបានដោយផ្នែក ពីថ្ងៃទី ១ មករា ២០០៤ ។
- *អធិការកិច្ចទំនិញមុនពេលផ្ទុក:* ចាប់ពីថ្ងៃចូលជាសមាជិក រដ្ឋាភិបាលនឹងទទួលខុសត្រូវពេញលេញក្នុងការធានាថា ប្រតិបត្តិការរបស់ក្រុមហ៊ុនអធិការកិច្ចទំនិញមុនពេលផ្ទុក ដែលភាគីកម្ពុជាបានអនុញ្ញាតឱ្យដំណើរការ នឹងសមស្របតាមតំរូវការនៃកិច្ចព្រមព្រៀង WTO ។ របបអធិការកិច្ចទំនិញមុនពេលផ្ទុករបស់កម្ពុជា នឹងស្ថិតនៅជាបណ្តោះអាសន្ន ហើយត្រូវបញ្ចប់នៅពេលទីចាត់ការគយនិងរដ្ឋាករ អាចបំពេញតួនាទីដែលបច្ចុប្បន្នធ្វើឡើងដោយក្រុមហ៊ុនផ្តល់សេវាកម្ម *អធិការកិច្ចទំនិញមុនពេលផ្ទុក* ។
- *របបការពារសុវត្ថិភាព ពន្ធគយសំរាប់ទប់ទល់ និងប្រឆាំងនឹងការលក់បង្ខូចថ្លៃ:* កម្ពុជានឹងមិនអនុវត្តវិធានការពារសុវត្ថិភាព ទប់ទល់ ឬប្រឆាំងនឹងការលក់បង្ខូចថ្លៃទេ រហូតដល់ខ្លួនបានប្រកាសនិងអនុវត្តវិធាន និងច្បាប់ដ៏សមស្របដោយគោរពតាមកិច្ចព្រមព្រៀង WTO ។ បន្ទាប់ពីនេះ កម្ពុជានឹងអនុវត្តពន្ធគយប្រឆាំងនឹងការលក់បង្ខូចថ្លៃ ពន្ធគយទប់ទល់ និងវិធានការការពារសុវត្ថិភាព លុះត្រាតែវាអនុលោមទាំងស្រុងទៅតាមបញ្ញត្តិពាក់ព័ន្ធរបស់ WTO ។
- *ការរឹតត្បិតលើការនាំចេញ:* កម្ពុជារឹតត្បិតការនាំចេញអង្ករ ឈើមូល ឈើមិនទាន់កែច្នៃ ផលិតផលព្រៃឈើ វត្ថុបុរាណមានអាយុកាលច្រើនជាង ១០០ឆ្នាំ ថ្នាំពុលនិងថ្នាំមានជាតិស្រវឹង អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ អាវុធយុទ្ធភ័ណ្ឌ យានយន្ត និងម៉ាស៊ីនសំរាប់យោធា ។ ចាប់ពីថ្ងៃចូលជាសមាជិក កម្ពុជានឹងធានាថា រាល់ការរឹតត្បិតត្រូវគោរពតាមកិច្ចព្រមព្រៀង WTO ។
- *ឧបត្ថម្ភធនលើការនាំចេញ:* កម្ពុជា នឹងគោរពតាមកិច្ចព្រមព្រៀងឧបត្ថម្ភធន បន្ទាប់ពីបានចូលជាសមាជិក WTO ។ ខ្លួននឹងលុបចោលប្រព័ន្ធលើកលែងកំរៃនាំចូល និងការលើកលែងពន្ធគយលើទំនិញខ្លះ ដែលប្រើប្រាស់ដោយវិនិយោគិន ឬក៏ដាក់ដំណើរការប្រព័ន្ធបង្វិលសងពន្ធគយមួយដែលស្របនឹងបញ្ញត្តិ WTO តាមរយៈការធ្វើវិសោធនកម្មច្បាប់វិនិយោគទុនយ៉ាងយូរបំផុតត្រឹមដំណាច់ឆ្នាំ២០១៣ ។
- *គោលនយោបាយឧស្សាហកម្ម និងឧបត្ថម្ភធន:* ឧបត្ថម្ភធនទាំងនេះត្រូវផ្តល់ដំណឹងជូន ចាប់ពីថ្ងៃចូលសមាជិក ។
- *ស្តង់ដារ និងការចេញលិខិតអនុញ្ញាត:* កម្ពុជា នឹងអនុវត្តជាបណ្តើរៗនូវកិច្ចព្រមព្រៀងរនាំងបច្ចេកទេសលើពាណិជ្ជកម្ម ។ ការអនុវត្តពេញលេញ នឹងចាប់ផ្តើមពីថ្ងៃទី ១ មករា ២០០៧ ដោយពុំមានរយៈពេលអន្តរកាលបន្ថែមទេ ។
- *វិធានការវិនិយោគទាក់ទិននឹងពាណិជ្ជកម្ម (TRIMs):* កម្ពុជា នឹងមិនរក្សាវិធានការណាមួយដែលផ្ទុយពីកិច្ចព្រមព្រៀង TRIMs ឡើយ ហើយនឹងអនុវត្តកិច្ចព្រមព្រៀងនេះ ចាប់ពីថ្ងៃចូលសមាជិកដោយពុំមានរយៈពេលអន្តរកាលបន្ថែម ។

- *អង្គភាពពាណិជ្ជកម្មរដ្ឋ:* កម្ពុជា នឹងអនុវត្តវិធាន និងច្បាប់ដែលគ្រប់គ្រងសកម្មភាពរបស់សហគ្រាសរដ្ឋ ដោយគោរពតាមយ៉ាងពេញលេញនូវបញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ។
- *តំបន់សេដ្ឋកិច្ចសេរី តំបន់សេដ្ឋកិច្ចពិសេស:* តំបន់សេដ្ឋកិច្ចសេរី ឬតំបន់សេដ្ឋកិច្ចពិសេស ក្នុងនេះមានទាំងតំបន់មានការទ្រទ្រង់ពិសេសដែលបង្កើតឡើងស្របតាមច្បាប់វិនិយោគ នឹងត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀង WTO យ៉ាងពេញលេញ និងក្រោមការប្តេជ្ញារបស់កម្ពុជាក្នុងពេលចូលសមាជិក WTO ។ កម្ពុជានឹងធានាអោយមានការអនុវត្តន៍កាតព្វកិច្ច WTO ទាក់ទិននឹងការបង្កើតតំបន់ទាំងនេះ ។ លើសពីនេះទៀត ទំនិញទាំងឡាយដែលផលិតចេញពីតំបន់នេះ ក្រោមការលើកលែងពន្ធ និងពន្ធគយ ព្រមទាំងការលើកលែងពន្ធលើវត្ថុធាតុដើម ត្រូវស្ថិតក្រោមទំរង់បែបបទពន្ធគយធម្មតា នៅពេលចូលទៅក្នុងតំបន់ផ្សេងទៀតនៅកម្ពុជា គឺមានការយកពន្ធ និងពន្ធគយ ។
- *ការឆ្លងកាត់:* កម្ពុជានឹងអនុវត្តវិធាន ច្បាប់ និងទំលាប់ ដែលទាក់ទិននឹងប្រតិបត្តិការនាំទំនិញឆ្លងកាត់ អោយស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀង WTO យ៉ាងពេញលេញ ។
- *គោលនយោបាយកសិកម្ម:* កម្ពុជា រឹតបន្តឹងឧបត្ថម្ភធនលើការនាំចេញផលិតផលកសិកម្មអោយនៅកំរិតសូន្យ និងមិនរក្សា ឬអនុវត្តឧបត្ថម្ភធនលើការនាំចេញលើផលិតផលកសិកម្មឡើយ ។
- *របបវាយនភណ្ឌ:* ចាប់ពីថ្ងៃចូលជាសមាជិក WTO ការកំណត់កូតាលើការនាំចូលវាយនភណ្ឌ និងសំលៀកបំពាក់ដែលប្រទេសសមាជិកដទៃបានដាក់លើការនាំចូលពីកម្ពុជា នឹងមានអត្រាកំនើនស្របតាមសេចក្តីចែងក្នុងកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសំលៀកបំពាក់ ។ អត្រាកំណើននេះ នឹងចប់នៅពេលកិច្ចព្រមព្រៀងវាយនភណ្ឌ និងសំលៀកបំពាក់ ត្រូវចប់ (ក្នុងឆ្នាំ២០០៥) ។
- *កម្មសិទ្ធិបញ្ញាជាប់ទាក់ទិននឹងពាណិជ្ជកម្ម (TRIPS):* កម្ពុជា នឹងអនុវត្តកិច្ចព្រមព្រៀង TRIPS មិនអោយយូរជាងថ្ងៃទី ១ មករា ២០០៧ ដោយមានកិច្ចការពារមួយចំនួនក្នុងរយៈពេលអន្តរកាល ។
- *តម្លាភាព:* រាល់បទប្បញ្ញត្តិ និងច្បាប់នានា ត្រូវបោះពុម្ពផ្សាយយោងទៅតាមការតំរូវផ្សេងៗរបស់ WTO និងដាក់លើគេហទំព័រអ៊ិនធឺណិត ចាប់ពីថ្ងៃ ១ មករា ២០០៤ ។

# ឧបសម្ព័ន្ធស្ថិតិ

*តារាង A.1 : វិនិយោគឯកជនតាមវិស័យ ឆ្នាំ១៩៩៥-២០០៤ ( លានដុល្លារ)*

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | 6.0 | 118.5 | 65.6 | 51.6 | 63.9 | 9.8 | 5.6 | 38.9 | 3.7 | 12.3 |
| ឧស្សាហកម្ម | 299.5 | 416.6 | 512.5 | 650.5 | 162.7 | 63.1 | 99.8 | 57.4 | 142.6 | 170.9 |
| សេវាកម្ម | 1937.4 | 231.6 | 166.5 | 154.7 | 222.6 | 150.1 | 111.4 | 143.3 | 167.7 | 91.8 |
| សរុប | 2242.9 | 766.7 | 744.5 | 856.8 | 449.1 | 222.9 | 216.8 | 239.6 | 314.1 | 275.0 |

*តារាង A.2 : វិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជា បានពីប្រទេសចិន ឆ្នាំ១៩៩៥-២០០៤ ( លានដុល្លារ)*

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| វិនិយោគទុនសរុប | 2243 | 767 | 744 | 854 | 448 | 218 | 205 | 238 | 250 | 210 |
| វិនិយោគផ្ទាល់ពីបរទេស | 1910 | 619 | 578 | 556 | 196 | 160 | 140 | 145 | 65 | 134 |
| វិនិយោគពីចិន | 3 | 38 | 36 | 105 | 46 | 28 | 5 | 24 | 33 | 77 |
| ជាវិស័យកាត់ដេរ | 0.13 | 5 | 16 | 23 | 12 | 0.7 | 1.7 | 3 | 7 | 32 |

*ប្រភព: គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)*

*តារាង A.3 : ការនាំចូលរបស់ចិនពីថៃ និងវៀតណាម នូវផលិតផល EHP ឆ្នាំ២០០០-២០០៥ ( ដុល្លារ)*

| លេខកូដ HS | ពិពណ៌នា | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| ថៃ | | | | | | |
| 0714 | ដំឡូងឈើ | 125,024,557 | 113,486,345 | 150,256,014 | 273,152,624 | 341,252,086 |
| 0810 | ផ្លែឈើស្រស់ | 61,950,157 | 58,365,048 | 60,030,316 | 121,214,993 | 117,806,851 |
| 0804 | ផ្លែល្មើ ល្វា ម្នាស់ អាវ៉ូកាដូ | 9,197,746 | 8,986,787 | 15,308,504 | 29,640,417 | 35,066,498 |
| 0303 | ត្រីបង្កក | 6,734,244 | 6,638,032 | 6,683,758 | 19,797,223 | 34,503,445 |
| 0813 | ផ្លែឈើក្រៀម | 636,387 | 1,612,394 | 5,897,865 | 27,337,427 | 21,910,297 |
| 0306 | សត្វវង្គសត្វ ( ក្តាម ឬ បង្កង) | 14,580,380 | 9,718,792 | 11,735,781 | 11,489,991 | 13,345,289 |
| 0307 | សិប្បិសត្វ ( ខ្យង គ្រំ) | 3,249,901 | 3,451,792 | 4,145,963 | 5,060,120 | 6,160,082 |

| លេខកូដ HS | ពិពណ៌នា | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| 0803 | ចេក ( ស្រស់ ឬ ស្ងួត) | 158,738 | 235,251 | 551,320 | 1,940,054 | 3,206,599 |
| 0304 | សាច់ចំឡក និងសាច់ដទៃនៃត្រី | 1,738,620 | 3,368,253 | 3,378,163 | 3,091,854 | 3,119,648 |
| 0805 | ក្រូចស្រស់ ឬស្ងួត | 497,905 | 860,755 | 736,643 | 439,453 | 1,613,569 |
| 0801 | ផ្លែដូង គ្រាប់ផ្លែឈើប្រេស៊ិល និងគ្រាប់ចាន់ទី | 22,944 | 91,621 | 161,966 | 441,451 | 454,196 |
| 0812 | ផ្លែឈើរក្សាទុកបណ្តោះអាសន្ន មិនទាន់អាចបរិភោគបានភ្លាម | 145,234 | 219,909 | 270,633 | 258,158 | 372,699 |
| 0301 | ត្រីរស់ | 146,586 | 250,991 | 60,594 | 225,752 | 362,957 |
| 0710 | បន្លែ | 152,891 | 34,213 | 39,033 | 196,853 | 272,644 |
| 0713 | បន្លែក្រៀមមានសំបក | 261,299 | 268,059 | 162,311 | 282,719 | 265,858 |
| 0305 | ត្រីងៀត ឬប្រឡាក់ | 333,191 | 212,460 | 770,156 | 296,850 | 254,216 |
| 0811 | ផ្លែឈើបង្កក | 7,004 | 12,340 | 9,073 | 80,761 | 62,798 |
| 0302 | ត្រីស្រស់ ឬត្រាំទឹកកក | 55,429 | 43,605 | 26,112 | 93,797 | 33,498 |
| 0709 | បន្លែផ្សេងទៀត | 92,756 | 99,170 | 102,404 | 76,794 | 19,009 |
| **វៀតណាម** | | | | | | |
| 0714 | ដំឡូងឈើ | 13,221,017 | 18,586,587 | 40,620,511 | 49,492,064 | 50,373,358 |
| 0306 | សត្វវង្គសត្វ ( ក្តាម ឬ បង្កង) | 4,458,984 | 1,700,387 | 1,575,617 | 4,311,145 | 8,559,855 |
| 0304 | សាច់ចំឡក និងសាច់ដទៃនៃត្រី | 676,123 | 711,484 | 3,815,307 | 6,663,969 | 8,524,803 |
| 0307 | សិប្បិសត្វ ( ខ្យង ឬគ្រុំ) | 2,663,104 | 5,822,056 | 3,607,061 | 3,851,195 | 5,869,177 |
| 0305 | ត្រីងៀត ឬ ប្រឡាក់ | 704,901 | 2,969,449 | 2,361,995 | 422,629 | 2,716,362 |
| 0303 | ត្រីបង្កក | 166,508 | 691,687 | 756,337 | 303,318 | 669,432 |
| 0711 | បន្លែរក្សាទុកបណ្តោះអាសន្ន មិនទាន់អាចបរិភោគបានភ្លាម | 129,712 | 312,024 | 192,026 | 314,268 | 257,166 |
| 0302 | ត្រីស្រស់ និងត្រីទឹកកក | 14,964 | 42,453 | 14,163 | 77,781 | 20,102 |
| 0713 | បន្លែក្រៀមមានសំបក | 7,272 | 99,676 | 79,982 | 184,966 | 14,981 |
| 0709 | បន្លែផ្សេងទៀត | 24,574 | 550 | - | - | 7,849 |

ប្រភព: Global Trade Atlas

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍកម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរថ្លៃ ៩.000រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.000រៀល ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១០. Gorman, Siobhan, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង វឿល-សុភាព (សីហា ២000) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១0.000រៀល ។

១៦. ស៊ិក បូរ៉ាក្ស (ធ្នូ ២000) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.000រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២00១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលួតលាស់ និងការកែតំរូវ ចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya (ខែធ្នូ ឆ្នាំ២00១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២0. សូ-សុវណ្ណារិទ្ធ វឿល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២00២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ៉ាក្ស, Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២00២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.000រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២00២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការ លក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (ខែកញ្ញា ឆ្នាំ២00២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា:* ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១0.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតានា និង Sarthi Acharya (ខែធ្នូ ឆ្នាំ២00២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.000រៀល អង់គ្លេស ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ខែធ្នូ ឆ្នាំ២00២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរតំលៃ ៨.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៦. Sarthi Acharya គីម-សេតានា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (ខែកញ្ញា ឆ្នាំ២00៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.000រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ខែធ្នូ ឆ្នាំ២00៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (ខែវិច្ឆិកា ឆ្នាំ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ ដុល្លារ ។

៣០. Caroline Hughes និង គីម សេតារា (ខែមិថុនា ឆ្នាំ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣.៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦.៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទូត សុខផល្លី (ឧសភា ២០០៥) សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥.០០ដុល្លារ ។

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ផ្តល់សារៈប្រយោជន៍ និងផលចំណេញសេដ្ឋកិច្ចដល់ប្រទេសសមាជិកទាំងអស់តាមរយៈការបង្កើនសកម្មភាពពាណិជ្ជកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច វិនិយោគ និងការពង្រឹងកិច្ចសហប្រតិបត្តិការ ។ ការលុបបំបាត់របាំងពាណិជ្ជកម្មរវាងអាស៊ានចិន អាចកាត់បន្ថយថ្លៃដើម បង្កើនសកម្មភាពពាណិជ្ជកម្មអន្តរតំបន់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និងកែលំអលទ្ធភាពវិនិយោគនៅក្នុងតំបន់ ។

សំរាប់ប្រទេសកម្ពុជា កម្មវិធីប្រមូលផលដើមដៃ ដែលមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ក្នុងគោលបំណងបង្កើនល្បឿនសេរីភាវូបនីយកម្មពាណិជ្ជកម្មលើផលិតផលកសិកម្ម អាចនឹងផ្តល់ឱកាសដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម ដែលជាប្រភពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

ការអភិវឌ្ឍន៍វិស័យកសិកម្មតាមកម្មវិធីនេះ អាចធ្វើទៅបានតាមរយៈការនាំចេញទៅទីផ្សារប្រទេសចិននូវផលិតផលមួយចំនួនដូចជា ផ្លែឈើស្រស់ សត្វចិញ្ចឹម ត្រី និងបង្គា។

---

ហ៊ីង វុត្ថា និង នូ កែវសុទ្ធា គឺជាអ្នកស្រាវជ្រាវនៅ វបសអ ។

**8.000** រៀល

ISBN: 99950-52-12-1

9789995052126

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
56 ផ្លូវ 315, ទួលគោក ភ្នំពេញ (ប្រអប់សំបុត្រ: 622 ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (855-23) 881-701/881-916/883-603
ទូរសារ: (855-23) 880-734
អ៊ីមែល: cdri@camnet.com.kh
http://www.cdri.org.kh